ទំនៀមទំលាប់ និង ប្រពៃណីខ្មែរ

398.20
9596
ន
ប. ១

អប់រំចរិយាសម្បត្តិ

2007

ទំនៀមទម្លាប់និងប្រពៃណីខ្មែរ

ឧកញ៉ាមហាមន្ត្រី

ញិក-នូវ

រៀបរៀង

បោះពុម្ពលើកទី ២

015776

ព.ស. ២៥០១ គ.ស. ១៩៥៨

រក្សាសិទ្ធិ

មាតិការឿង

ទំព័រ

តែងខ្លួន ១
សំលៀកបំពាក់ ២
ទៅវត្ត ៣
ស្បែកជើង ៥
មួក និងឆ័ត្រ ៩
គ្រឿងអលង្ការ និងគ្រឿងក្រអូប ៩
សំលៀកបំពាក់ទៅបុណ្យខ្មោច-កាន់ទុក្ខ ១០
ការសក់កាន់ទុក្ខ ១៣
រយៈពេលកាន់ទុក្ខ ១៤
មិត្រ និងព្រៀងលាន ១៦
អ្នកបួសមុខភ្លើង ១៧
សំលៀកបំពាក់ក្នុងឱកាសរៀបមង្គលការ ១៨
សំលៀកបំពាក់ក្នុងឱកាសលៀងក្រយាហារ ២១
សំលៀកបំពាក់ធ្វើការងារ ២៤
សំលៀកបំពាក់ដើរកំសាន្ត ២៥
សំលៀកបំពាក់ទៅលេងផ្ទះបងប្អូនឬមិត្រសំឡាញ់ ២៨
សំលៀកបំពាក់នៅផ្ទះ ២៩
សំលៀកបំពាក់ជាផ្លូវការ ៣១

សំលៀកបំពាក់ក្នុងព្រះរាជពិធីផ្សេងៗ ៣៤
សំលៀកបំពាក់តាមរដូវ ៣៦
សារុង ៣៨
ក្រមាពញាក់ ៣៨
ពណ៌សំពត់ស្លៀកតម្រូវតាមថ្ងៃ ៣៩
សក់-ពុកមាត់-ពុកចង្ការ-ក្រចក ៣៩
បន្ទាប់ទទួលភ្ញៀវ..៤១
ភ្ញៀវ និងអ្នកផ្ទះ..៤៣
ការលាគ្នា ៤៨
ជូនដំណើរភ្ញៀវ ៥០
ការនាំឱ្យស្គាល់គ្នា ៥១
តាមរបៀបអារ្យធម៌សម័យនិយម...៥៣
របៀបនាំភ្ញៀវឱ្យស្គាល់គ្នា...៥៤
របៀបនិយាយនាំភ្ញៀវឱ្យស្គាល់គ្នា...៥៤
កិច្ចគួរសមតាមផ្លូវ..៥៨
លៀងក្រយាហារ ៦០
របៀបបរិភោគអាហារ...៦៣
លក្ខណៈដែលនឹងបរិភោគឱ្យល្អ ៦៤
ថ្នាំជក់...៦៨

តែងខ្លួន

ការរៀបចំតាក់តែងខ្លួនប្រាណក៏ជាកិច្ច១ដ៏សំខាន់ ដែលយើងរាល់គ្នា មិនថាបុរស ឬ ស្ត្រីឡើយ ត្រូវរិះគិតឱ្យម៉ត់ចត់ ព្រោះការតែងខ្លួន នេះបើមិនស្លៀកពាក់ឱ្យសមរម្យ ឱ្យត្រឹមត្រូវតាមលក្ខណបុណ្យ ឬពិធីណាមួយ ដែលគេចាត់ចែងនោះទេ យើងនឹងត្រូវទទួលសេចក្តីរិះគន់ចំអកឡកឡឺយអំពីអ្នកដទៃមិនខាន ។

យើងគប្បីព្យាយាម គយគន់អ្នកទាំងពួងតែងខ្លួន ដែលសមរម្យតាមចាស់ តាមក្មេង កុំគប្បីទៅចំណាំពេញចិត្ត នឹង ពណ៌សំពត់ ពណ៌ព្រៃ ។ ការរៀបចំខ្លួនក្មេង នឹងចាស់ពុំដូចគ្នាទេ បើចាស់ទៅតែងខ្លួនដូចក្មេងក៏ពុំសម ក្មេងតែងខ្លួនដូចចាស់ក៏ពុំសម ។ ឯដំណើរអ្នកមាន ឬអ្នកក្រខ្សត់ អ្នកធំ ឬ អ្នកតូចឥតមានជំទាស់ថាអ្វីទើយ ស្រេចហើយតែនឹងមានទ្រព្យ ធ្វើបានត្រឹមណាយកត្រឹមណោះជាខ្នាតទៅចុះ កុំឱ្យតែធ្វើឱ្យហួសប្រមាណខ្លួន ។

គ្រឿងប្រដាប់សម្រាប់តែងខ្លួន ខ្ញុំញែកជា៣ជំពូកឱ្យដាច់ពីគ្នាគឺ : សំលៀកបំពាក់១ គ្រឿងអលង្ការ ១ គ្រឿងក្រអូប ១ ។

គ្រឿងប្រដាប់ដែលមាននៅក្នុងជំពូកទាំង៣ នេះ មិនមែនប្រើទៅសមរម្យបានគ្រប់គ្នាទេ ។

*

* *

សំលៀកបំពាក់

យើងកុំគប្បីសំគាល់ពណ៌ព្រៃ ឬសំពត់ទាំងឡាយថាល្អ ហើយសម ហើយយកជាប្រមាណនោះឡើយ ។ ព្រោះថា សំពត់អម្បោះក្តី ។ល។ រមែងមានពណ៌ផ្សេងៗគ្នា ដូច្នេះយើងត្រូវរើសយកពណ៌ណា ដែល សមល្មម នឹងសម្បុរស្បែកយើង ពណ៌ណាសមនឹងចំណាស់យើង ទោះបីមានផ្កា ឬលាតក៏កុំឱ្យមានទំនាស់ពុំសមរម្យ នឹងរូបចោមលោមពណ៌របស់ យើង ។

សម្លៀកបំពាក់នេះ ត្រូវចែកទៅទៀតតាមទម្លាប់ទំនៀមផង តាម សម័យនិយមផង តាមផ្លូវការផង តាមរដូវផង ។

ក-តាមទម្លាប់ទំនៀមនឹងសម័យនិយម យើងគប្បីស្លៀកពាក់ឱ្យ ត្រូវ តាមទម្លាប់ទំនៀមរបស់ស្រុកនោះតើនៅពេលណាខ្លះ ?

ខ្ញុំយល់ថា ត្រូវស្លៀកពាក់ឱ្យសមរម្យផង ឱ្យត្រូវតាមទម្លាប់ ទំនៀមស្រុកផង ឱ្យត្រូវតាមសម័យនិយមផង ក្នុងពេលដូចមានតទៅនេះ:

១-ទៅវត្ត (ក្នុងឱកាសបុណ្យក្តី ឥតបុណ្យក្តី) ។

២-ទៅបុណ្យខ្មោច គឺសពនៅលើផ្ទះ ឈាបនកិច្ចបញ្ចុះធាតុ ។

៣-ទៅក្នុងពិធីមង្គលការអាពាហ៍ពិពាហ៍ ។

៤-ទៅធ្វើការងារផ្សេង ៗ ។

៥-ទៅដើរកំសាន្ត ។

៦-ទៅលេងផ្ទះបងប្អូន - មិត្តសំឡាញ់ ។

៧-នៅផ្ទះ ។

ការកាន់ទម្លាប់ទំនៀមជាការប្រសើរណាស់ ក៏ពិតមែនហើយ ប៉ុន្តែទម្លាប់ឯណាដែលប្រែប្រួលទៅតាមសម័យនិយម ហើយទម្លាប់នោះមិនអាចនៅជាទំនៀមតទៅទៀតបានឡើយ ។

រឿងសម្លៀកបំពាក់នេះផ្លាស់ប្ដូរច្រើនបែបណាស់ ស្ទើរតែ ១ឆ្នាំម្ដង១ ។ តែសំរាប់ចូលគាល់ព្រះរាជាក្ដី មង្គលការអាពាហ៍ពិពាហ៍ក្ដី កាន់ទុក្ខក្ដី ពុំទាន់មានផ្លាស់ចោលទម្លាប់ទំនៀមចាស់បុរាណជាច់ស្រឡះនៅឡើយទេ ។

*

*   *

១_ទៅវត្ត

ស្ត្រី និង បុរសមានរបៀបរៀបចំខ្លួនប្រាណទៅវត្ត ប្រកបដោយដំណើរសង្រួមតាំងពីឫកពា ព្រមទាំងសម្លៀកបំពាក់ទៀតផង ឱ្យល្មមសមរម្យ កុំប្រើពណ៌ឱ្យឆើតឆាយពេក ។ សំពត់អាវដែលស្លៀកពាក់ទៅវត្តក៏គប្បីបិទបាំង រូបកាយឱ្យបានគត់មត់ល្អ ។ សម្រាប់ស្ត្រីត្រូវប្រយ័ត្នកុំឱ្យស្លៀកពាក់ខើចពេក ខ្លីពេក ឬចំហរមុខក្រោយ ឱ្យលេចឃើញទី ដែលបង្កើតឡើងនូវតម្រេកដល់បុរស ។

យើងដឹងហើយថា ព្រះសង្ឃលោកជាអ្នកខ្ពើមកាមរោគ លោកតែងចោលសម្បត្តិគ្រហស្ថក្នុងលោកិយនេះ ប្រាថ្នាកោសរូសកិលេសឱ្យស្រាលស្តើង ។ លោកតាំងអារាមទីលំនៅគណៈលោកដោយឡែក ដើម្បីសេចក្តីស្ងប់ស្ងាត់នេះ១ ដើម្បីធ្វើសីលឱ្យបរិសុទ្ធិនេះ១ ដើម្បីសេចក្តីសុខក្នុងលោកនេះ និងលោកឯមុខនេះ១ ។ ចុះបើស្ត្រីធ្វើឫពារជាដំណើរមិនគួរគប្បីនៅមុខលោក១ នៅជាបុផ្ជូនដែរ ក៏គង់តែមានដួងហឫទ័យវិបល្លាសប្រែប្រួលខ្លះមិនលែង ។ ដូច្នេះស្ត្រីចូលវត្តគប្បី ប្រើកាយវាចាឫកពា និងសំដីឱ្យសមរម្យ កុំឱ្យស្និទ្ធស្នាលនិង លោកសង្ឃពេក ។

បុរសគេធ្លាប់ស្លៀកសំពត់ចងក្បិន ខោចិន ពាក់អាវកុត ឬអាវចិនប៉ុណ្ណោះល្មមហើយ យើងមិនចាំបាច់ក្រវាត់ក្រមាពីលើអាវទៀតទេ ។ តែបើរៀបចំខ្លួនប្រាណតាមទំនើបថ្មីក៏បាន កុំតែពាក់ស្បែកជើងឡើងកុដិលោកឡើងព្រះវិហារ ឬព្រះចេតិយ (ចូរមើលសេចក្តីអធិប្បាយនៅទំព័រខាងក្រោម) ។

ស្ត្រីគេធ្លាប់ស្លៀកសំពត់ចងក្បិន សំពត់សំឡុយ ឬ ខោ្សន ពាក់អាវបំពង់ខ្លី ឬអាវបំពង់វែង តែគេតែងមានក្រមាដណ្តប់បិទទ្រូងទៀតនេះ ជាការចាំបាច់ លើកលែងតែស្ត្រីព្រហ្មចារីចេញ គេឥតរិះគន់ទេ ។ ដល់មកសតវត្សរ៍នេះ អារ្យធម៌អឺរ៉ុបចូលមក សម្លៀកបំពាក់បណ្តាជនផងទាំងពួងក៏ចំរើនទៅតាមបែបផែននោះដែរ ព្រមទាំងការរចនាផ្សេងៗទៀត ក៏ល្អ

លើសលុបជាងពី សម័យបុរាណច្រើនបែបច្រើនយ៉ាងណាស់ ហើយប្លែក ៗ គ្នាផង ។

ត្រង់នេះ ស្ត្រីត្រូវចាំកុំភ្លេចថា បើរៀបខ្លួនប្រាណទៅវត្ត កុំគប្បីប្រើសំពត់ និងអាវ ដែលមានព័ណ៌នោះឆើតឆាយពេកកុំគប្បីពាក់អាវឥតដណ្តប់ក្រមា កុំគប្បីពាក់អាវរៀលកធំពេក ហើយគ្មានដៃនោះ ។

គប្បីប្រើព័ណ៌យ៉ាងខ្ចីយ៉ាងស្រគាំ ស ឬខ្មៅ អាវរៀលកឱ្យតូចល្មមមានដៃវែង ឬខ្លីល្មម ហើយត្រូវដណ្តប់ក្រមាទៀត ទើបសមរម្យជាអ្នកចូលវត្ត (បើពាក់អាវសសមជាងគេបំផុត) ។

* *
*

ស្បែកជើង

តាមសម័យនេះ គេរាប់អានប្រើទ្រនាប់ជើង (ស្បែកជើង) ដើម្បីការពារបាតជើងកុំឱ្យប៉ះទង្គិច ឬមុត និងការពារក្តៅត្រជាក់ផង ជារបៀបតែងខ្លួនតាម ទម្លាប់អឺរ៉ុបផង។

ចំណែកខាងគារវកិច្ច របស់គ្រហស្ថបែកខាងអ្នកកាន់ព្រះពុទ្ធសាសនាវិញ ស្បែកជើងពាក់ចូលវត្តមានការទាស់ខុសជាច្រើនប្រការ :

១-ព្រះសង្ឃដែលគ្មានពាក់ស្បែកជើង

មិនត្រូវនិយាយស្តីនឹងគ្រហស្ថ ដែលពាក់ស្បែកជើងទេ ។ បើពាក់ដូចគ្នាមិនជាការទាស់ខុសទេ ។

២-គ្រហស្ថមិនត្រូវពាក់ស្បែកជើងឡើងកុដិលោកសង្ឃ ឬឡើងព្រះវិហារ ព្រះចេតិយទេ ។ ត្រូវដោះទុកនៅកាំជណ្តើរខាងក្រោម ទើបរួចទោសកំហុសក្នុង គារវកិច្ច ។

ចំណែកព្រះវិហារ និងព្រះចេតិយនេះ ត្រូវយើងជាអ្នកចេះអប់រំថ្វាយបង្គំព្រះពុទ្ធ ចេះហាមខ្លួនយើងផង ហាមអ្នកដទៃផង ដែលពុំបានដឹងជាក់ក្នុងគារវកិច្ចថា: "កុំឱ្យពាក់ស្បែកជើងឡើង", ចុះបើមានជនបរទេសដែលជាអ្នកមិនកាន់ព្រះពុទ្ធសាសនានោះ, អ្នកចាំព្រះវិហារ ទោះព្រះសង្ឃក្តី គ្រហស្ថក្តីគប្បីប្រាប់ ពន្យល់ឱ្យដឹងផងថា "ត្រូវតែដោះស្បែកជើងទើបចូលបាន" ។ យ៉ាងនេះហើយទើប សមរម្យនឹងឈ្មោះដែលហៅថា អ្នកកាន់ព្រះពុទ្ធសាសនា ។

តួយ៉ាងដូចជានៅវត្តព្រះកែវមរកត រាជវរារាម ក្រុងភ្នំពេញសព្វថ្ងៃនេះ មានជនបរទេសចូលមកមើលគ្មានលស់ថ្ងៃណាមួយសោះឡើយ តែទៅដល់ព្រះវិហារហើយ ពួកមគ្គុទេសក៏ (អ្នកនាំផ្លូវ) ព្រះរាជវាំងពន្យល់ឱ្យដោះស្បែកជើងសិន ទើបឱ្យឡើងចូលមើល ។ មិនតែប៉ុណ្ណោះមានទាំងបំរាមបិទនៅសន្លឹកទ្វារទៀត ប្រាប់ឱ្យដោះស្បែកជើង និងមួក ។ បញ្ញត្តិនេះមិនមែនក៏រិតតែលើអ្នកតូចទេ ទោះជាអ្នកធំក៏សុំឱ្យដោះស្បែកជើងជាដរាប ។ សូម្បីតែព្រះករុណាជាម្ចាស់ផែនដី ព្រះអង្គក៏ទ្រង់បំពេញគារវកិច្ចបានបរិបូណ៌ ព្រះអង្គទ្រង់ដោះព្រះសុព័ណ៌បាទទុកសិន បានស្តេចយាងចូលព្រះវិហារ ។

ខ្ញុំពោលរាប់របៀបយ៉ាងនេះ ហាក់ដូចចាមើលងាយលោក-អ្នកពេក ។ មិនមែនដូច្នោះទេ ព្រោះខ្ញុំបានឃើញក្មេងកម្លោះជំទង់ និងក្រមុំជាច្រើននាក់ពាក់ស្បែកជើងឡើងព្រះវិហារ-ព្រះចេតិយ ប្រហែលពុំបានដឹងវិន័យក្នុងគារវកិច្ច ដែលយើងរាល់គ្នាត្រូវសម្តែងសេចក្តីគោរព ចំពោះព្រះពុទ្ធព្រះធម៌ ព្រះសង្ឃ ។

ដូច្នេះដំណើរទៅវត្ត-ជាដំណើរទៅរកបុណ្យ មិនប្រមូលយកបុណ្យត្រឡប់ទៅជាឱបក្រសោបវេចយកបាបមកផ្ទះវិញ ដោយទោសខុសក្នុងគារវកិច្ចនោះទេ ។ នេះជាការគួរឱ្យស្តាយពេកណាស់ សម្រាប់យើងជាអ្នកថ្វាយខ្លួនក្នុងព្រះពុទ្ធ សាសនា ។

៣-ស្បែជើងនេះចែកត្រឹមពីរជំពូកទៅចុះ គឺស្បែកជើងឃ្ពុបជិតជើង និងស្បែកជើងមិនឃ្ពុបជិតជើង ។

ក-ស្បែកជើងឃ្ពុប គឺស្បែកជើងខ្ចី (Soulier) ស្បែកជើងកវែង (Bottine) នេះបើយើងរៀបខ្លួនត្រឹមត្រូវ គឺស្លៀកសំពត់ ពាក់អាវកុត ឬអាវបើកកចងក្រវាត់ ស្បែកជើងស្រោមជើង ឬតែងខ្លួនរបៀបអឺរ៉ុប ហើយទៅផ្ទះគ្រហស្ថដូចគ្នានោះ ត្រូវពាក់បានរហូតដល់ទីកន្លែងដែលគេទទួលយើង មិនត្រូវដោះទុកនៅខាងក្រៅទេ កុំគិតខ្លាចថាព្រោះអ្នកធំ ឬផ្ទះចៅហ្វាយនាយឱ្យសោះ លោកអ្នកធំ លោកពុំប្រកាន់ទេ លោកជ្រាបរបៀបសព្វគ្រប់អស់ហើយ ។ បើដោះស្បែកជើងនេះ ចេញវិញទៅជាជំទាស់នឹងទម្លាប់អារ្យធម៌អឺរ៉ុបទៅវិញ ។

ខ-ស្បែកជើងមិនឃ្លុបជិត ត្រូវរាប់យកស្បែកជើងផ្ទាត់គ្រប់បែបយ៉ាង និងស្បែកជើងឈើ ។

បើយើងពាក់ស្បែកជើងផ្ទាត់ ឬស្បែកជើងឈើទៅវត្ត ត្រូវដោះទុកនៅកាំជណ្ដើរក្រោមជាដរាប នៅព្រះវិហារក៏ដោយកុដិលោកក៏ដោយ ។

តែបើទៅផ្ទះគ្រហស្ថដូចគ្នាវិញ ស្បែកជើងឈើត្រូវទុកនៅកាំជណ្ដើរក្រោមបង្អស់ ។ ឯស្បែកជើងផ្ទាត់ ពាក់ឡើងទៅលើផ្ទះគេបានតែត្រឹមមាត់ទ្វារ មុខ ។

គ-ស្បែកជើងសង្រែក ពាក់បានតែដើរលេង ទៅវត្ត-ទៅធ្វើការងារ ព្រោះបើមានការត្រូវដោះចេញ យើងនឹងដោះបានដោយងាយ ។ តែបើយើងពាក់ ទៅរកអ្នកធំ មានគាល់ព្រះមហាក្សត្រក្ដី ក្សត្រធំៗក្ដី រដ្ឋមន្ត្រីក្ដី នេះមិនបានជាដាច់ ខាត ។ សូម្បីតែទៅទទួលល្បៀងក្រយាហារក្នុងឱកាសផ្សេងៗ នោះស្បែកជើង សង្រែកក៏មិនសមរម្យនឹងពាក់ទៅទេ ។ ស្បែកជើងសង្រែកទុកដូចជាស្បែកជើងផ្ទាត់ដែរ ។ ស្បែកជើងសង្រែកមិនទុកជាគ្រឿងប្រដាប់មួយដែលប្រើប្រាស់បាន ដូចជាស្បែកជើងឃ្លុបជិតជើងទេ ។

* *
*

មួកនិងឆ័ត្រ

ពួកពុទ្ធមាមកៈ មិនត្រូវពាក់មួក ឬបាំងឆ័ត្រដើរកាត់វត្តឡើយ សូម្បីតែដើរកាត់មុខវត្ត ក៏ត្រូវតែដោះមួកពីក្បាលចេញ ឬបិទឆ័ត្រដើរឱ្យផុតពីវត្តទៅសិន ចាំពាក់-បាំងតទៅទៀត ។ អ្នកដែលគេកាន់គារវកិច្ចយ៉ាងមាំទាំ គេតែងលើកដៃថ្វាយបង្គំព្រះថែមទៀតផង កាលណាគេដើរទៅដល់មុខព្រះវិហារ ។ តែប្រសិនជា ដើរទៅប្រទះនឹងភ្លៀងបង្អុរមកនោះគប្បីបាំងឆ័ត្រទៅចុះ ឯមួកហាមដាច់ខាតមិនត្រូវពាក់ដើរចូលទៅក្នុងវត្ត ឬកាត់មុខវត្តឱ្យសោះ មិនថាពេលណាជាពេលណាឡើយ ។

មិនតែប៉ុណ្ណោះទេ ដូចជាទូទូរសំពត់ ឬជូតក្បាលក៏ត្រូវមានកិច្ចគារវវត្តដូច គ្នានឹងពាក់មួកដែរ ។

* *
*

គ្រឿងអលង្ការនិងគ្រឿងក្រអូប

ស្រីៗស្រឡាញ់សម្លៀកបំពាក់ ស្រឡាញ់គ្រឿងអលង្ការ និងគ្រឿងក្រអូបជាទីបំផុតចិត្តក៏មែនពិតហើយ តែវេលាទៅវត្តគួរគប្បីកុំតែងខ្លួនឱ្យហួសមាឱពេក ។ ខ្ញុំបានអធិប្បាយហើយ អំពីសម្លៀកបំពាក់ទៅវត្ត ។ ទីនេះត្រូវបរិយាយអំពីគ្រឿងអលង្ការ និងគ្រឿងក្រអូបតទៅទៀត ។

ការរៀបចំខ្លួនប្រាណទៅវត្ត ហើយប្រដាប់ទៅដោយគ្រឿងអលង្ការ និងគ្រឿងក្រអូបនោះ មិនមែនឃាត់ហាមទេ តែត្រូវពាក់គ្រឿង

មាសពេជ្រឱ្យល្មម កុំឱ្យច្រើនពេក ព្រោះការធ្លាប់ពាក់ទៅហើយ ក៏ពាក់ខ្លះទៅចុះ ដោយមិនធ្លាប់ខ្លួនទទេ ។ ឧបមាដូចខ្សែដៃយ៉ាងតូច១ជុំម្ខាង និង ចិញ្ចៀន១វង់ សម្រាប់អ្នកនៅក្នុងវ័យកណ្ដាល ។ បើគេក្មេងអាចនឹងថែម ខ្សែក ឬទំហូទៀតក៏មិនហួសប្រមាណដែរ ។ តែបើសក់ស្កូវព្រោងទៅ ហើយខ្សែក និងទំហូក៏ផុតពេលវេលាទៅដែរ ។

ឯទឹកអប់មិនត្រូវលាបច្រើនពេក ឱ្យទាល់តែធ្មើលគេឯងទេ គឺថា ក្រអូបអស់មួយកុដិ ឬមួយសាលានោះ ។ ម្សៅទៀតក៏កុំប្រផូរពេក បបូរ មាត់ក៏កុំឱ្យក្រហមពេកដែរ ។ មូលសេចក្ដីទៅថាមិនត្រូវតែងខ្លួនឱ្យដូច ដើរមើលបុណ្យង៉ាន ឬដើរលេងកំសាន្តធម្មតានោះទេ ចូលវត្តត្រូវតែកាន់ កិរិយាសុភាពជាដរាប ។

២.សម្លៀកបំពាក់នៅបុណ្យខ្មោច.កាន់ទុក្ខ

អ្នកដែលជាសាច់សាលោហិត នឹងអ្នកដែលដល់នៅមរណកាល ទោះញាតិជិតក្ដី ឆ្ងាយក្ដី គប្បីសម្ដែងកិរិយាព្រមទាំងវាចាឱ្យជាក់ថា ខ្លួន មានសេចក្ដីទុក្ខសោក ដោយសេចក្ដីព្រាត់ប្រាសញាតិសន្ដានម្នាក់ ក្នុងវេលា នោះដែរ ។

ពេលដែលសពតម្កល់នៅលើផ្ទះ ត្រូវផ្លាស់សំពត់អាវដែលមានពណ៌ ឆើតឆាយ (ក្រហម-លឿង-បៃតង) នោះចេញ គឺត្រូវស្លៀកសពាក់សវិញ ជាសញ្ញា សំគាល់ឱ្យគេដឹងថា យើងជាអ្នកកាន់ទុក្ខ (នេះតាមបុរាណកាល របស់ខ្មែរ) ។ ចំណេរតមកការកាន់ទុក្ខនេះក៏ប្រែប្រួលបន្ដិចម្ដង១តាម

អារ្យធម៌ នៃប្រទេសអឺរ៉ុប ។ អ្នកខ្លះយល់ថា បើសពនោះត្រូវជាកូន-ប្អូន-ចៅ ក្មួយនោះ ពួកស្រីៗ គឺជីដូន ម្ដាយ-បងស្រី-ម្ដាយធំ-ម្ដាយមីង គប្បីស្លៀកពាក់ខ្មៅ ។ ចំណែកប្រុសៗវិញ គឺ ជីតា-ឪពុក-បងប្រុស-ឪពុកធំ-ឪពុកមា គប្បីស្លៀកខ្មៅពាក់ស (នៅផ្ទះក៏ដូចជា ថ្ងៃហែសពទៅធ្វើឈាបនកិច្ចដែរ) ។

ឯអ្នកដែលត្រូវជាប្អូន-ក្មួយ-ចៅ របស់សពទាំងប្រុសទាំងស្រី ត្រូវស្លៀកសពាក់សទាំងអស់ ។ ដល់អារ្យធម៌ប្រទេសអឺរ៉ុបចូលមក ប្រុសៗឈប់ប្រកាន់ថា បងឬប្អូន-កូនឬឪពុក-ចៅឬជីតា... ។ល។ តែកាលណាមានទុក្ខ ដោយដំណើរបាត់បង់សាច់សន្ដានហើយ តែងតែប៉ានដៃខ្មៅនៅដៃអាវខាងឆ្វេងទៀតជាសំគាល់ ។ តមកទៀតប៉ានដៃខ្មៅនេះក៏មានអ្នកខ្លះនៅប្រើ អ្នកខ្លះគ្រាន់តែយក សំពត់ខ្មៅប្រមាណជា២សង់ទីម៉ែត្រទទឹង១០សង់ទីម៉ែត្របណ្ដោយមកខ្ទាស់ ភ្ជាប់នឹងផ្នត់អាវបើកក ឬអាវអ្វីមួយដែលតមកក្រោបត់ខាងឆ្វេង ។

សេចក្ដីសង្ខេប នៃសម្លៀកបំពាក់កាន់ទុក្ខបុរសនៅថ្ងៃរំលាយសព ឬបញ្ចុះសព ត្រូវស្លៀកពាក់សសុទ្ធប៉ានដៃខ្មៅនឹងក្រវ៉ាត់ខ្មៅ ស្បែកជើងសក៏បាន ខ្មៅក៏បាន ។ ថ្ងៃតទៅប្រើខោអាវពណ៌ប្រផេះស្រគាំ គួរតែក្រវ៉ាត់នៅចងខ្មៅដដែល ត្រូវកុំផ្លាស់ពណ៌ដទៃទៀតឱ្យសោះ លុះត្រាតែគ្រប់កំណត់វេលា ដែលសន្មត់ទុកក្នុងចិត្តតាមរបៀបកាន់ទុក្ខ ដែលនឹងមានសម្ដែងតទៅខាងក្រោយ ។

ស្ត្រីក៏មានរបៀបរក្សាពណ៌សំពត់អាវ ឱ្យទៀងទាត់ដូចជាបុរសដែរ គ្មានតែបានដៃនឹងក្រវាត់កប៉ុណ្ណោះ ។

គ្រឿងតែងខ្លួន អ្នកដែលស្លៀកពាក់កាន់ទុក្ខ (ខ្មៅក្តី សក្តី) គប្បីតែឈប់ពាក់គ្រឿងមាសពេជ្រជាដាច់ខាត លុះត្រាតែដល់ថ្ងៃលែងកាន់ទុក្ខនោះ ។ បើកាន់ទុក្ខហើយមិនពាក់មាសពេជ្រ ហើយការលាបលនប្រេងម្សៅ និងបបូរមាត់ ក្រហម ក៏ត្រូវបង្អង់សិនដែរ ។

ខ្ញុំបានសំគាល់ឃើញមានស្ត្រីខ្លះ មានទុក្ខដោយប្តីស្លាប់ ហើយតាំងចិត្តថា លែងយកប្តីទៀត ។ អ្នកទាំងនោះរក្សាកិរិយាមារយាទបានល្អបរិសុទ្ធផុតអស់មួយជីវិតឈប់គិតក្នុងការតែងខ្លួន គេគិតតែកោរសក់ស្លៀកសពាក់សជណ្តប់ស ។ ខ្លះដែលទ័លក្រ ធន់ទ្រាំនឹងស្លៀកសពាក់សពុំបានក៏គ្រាន់តែកោរសក់ ហើយស្លៀក ពាក់សខ្លះខ្មៅខ្លះ ឬពណ៌ណាដែលប្រផេះស្រគាំខ្លះ មិនឆើតឆាយអស់១ជីវិតបាន ។ យើងគួរសរសើរស្ត្រីជំពូកនេះដែលមានចរិយាល្អ ប្រព្រឹត្តកាន់ក្រិត្យវិន័យ ឱ្យស្អាតមិនឱ្យមានពាក្យអ្នកផងរិះគន់បានឡើយ ។

* *
*

កោរសក់កាន់ទុក្ខ

ការកោរសក់ស្លៀកសពាក់សនេះ ជាទម្លាប់ទំនៀមរបស់ជនជាតិខ្មែរជាន់ដើម ជាសញ្ញាសំគាល់ថា អ្នកនោះឯងកាន់ទុក្ខ ដោយមានសាច់សាលោហិត យ៉ាងជិតទទួលមរណភាព ។

ប្រពន្ធត្រូវកោរសក់ កាន់ទុក្ខប្តី ។

ប្តីមិនត្រូវកោរសក់ កាន់ទុក្ខប្រពន្ធទេ ។

កូនត្រូវកោរសក់កាន់ទុក្ខមាតាបិតា ។ ចៅបង្កើតត្រូវកោរសក់ កាន់ទុក្ខជីដូនជីតា ។ សិស្សានុសិស្សត្រូវកោរសក់កាន់ទុក្ខលោកគ្រូ-បាអាចារ្យឧបជ្ឈាយ៍ ។ កូនក្មួយខ្លះ ដែលគេស្រឡាញ់ម្តាយធំ-ម្តាយមីង ឪពុកធំ-ឪពុកមា ក៏គេកោរសក់ កាន់ទុក្ខដែរ ។

ឯពួកមនុស្សបម្រើក្នុងផ្ទះ ដែលពុំមែនជាញាតិសន្តាន យើងជាម្ចាស់សព ដែលមានទ្រព្យសម្បត្តិគ្រាន់បើ ចង់ឱ្យមនុស្សទាំងនោះចូលកាន់ទុក្ខជាមួយផង ក្នុងរវាងថ្ងៃធ្វើបុណ្យ នោះយើងអាចចែកសំពត់អាវស ឱ្យស្លៀកពាក់ផងក៏មិនទាស់ អ្វី ជូនកាលគេឱ្យកោរសក់ទៀតផង ។

* *
*

រយៈពេលកាន់ទុក្ខ

កំណត់ពេលកាន់ទុក្ខ មិនជាទម្លាប់បង្ខំថា ប៉ុន្មានឆ្នាំ ប៉ុន្មានខែឡើយ ស្រេចហើយតែទ្រាំទ្របាន ព្រោះការកាន់ទុក្ខនេះ មិនមែនជាសម្លៀកបំពាក់សម្រាប់តាក់តែងខ្លួនប្រាណឱ្យល្អស្រស់នោះទេ ។ យើងដឹងខ្លួនយើងច្បាស់ណាស់ហើយថា យើងមានទុក្ខ ថាយើងមិនសុខមិនសប្បាយ ថាយើងសោក

ស្តាយស្រណោះ អាឡោះអាល័យ ដល់អ្នកដែលព្រាត់ប្រាសបាត់បង់ទៅ ដូច្នេះហើយមិនត្រូវថា ស្បៀកខ្មៅពាក់ខ្មៅ ឬស្បៀកសពាក់ស ឬហ៊ានខ្មៅនៅអាវនោះ អាចនឹងធ្វើឱ្យខ្លួន យើងល្អស្រស់ជាងធម្មតានោះទេ ។

តាមរបៀបទម្លាប់ស្រុកអឺរ៉ុប គេចែកពេលកាន់ទុក្ខនេះជាថ្នាក់ៗគេឱ្យឈ្មោះថា "ទុក្ខធំ" និង "ទុក្ខពាក់កណ្តាល" ។ នោះស្ត្រីមេម៉ាយ គេកាន់ទុក្ខអស់រវាង ២ឆ្នាំ, បុរសពោះម៉ាយគេកាន់ទុក្ខអស់រវាង១ឆ្នាំជាកំណត់ ។ គេកាន់ទុក្ខ៦ខែ សម្រាប់មាតាបិតាជីដូនជីតា-បងប្អូនស្រីប្រុសបង្កើត-បងថ្លៃ-ប្អូនថ្លៃ, ៣ខែសម្រាប់មា-មីង ឪពុកធំ-ម្តាយធំ, ៦សប្តាហ៍សម្រាប់បងប្អូនជីដូនមួយ-ម្តាយឪពុកចិញ្ចឹម (ម្តាយធម៌ ឪពុកធម៌) ។ បើកូនក្មេងការកាន់ទុក្ខនេះមិនជាការបង្ខំទេ ។

សូមចាំកុំភ្លេចថា ការកាន់ទុក្ខនេះពិបាកបន្តិចហើយ ត្រូវគោរពនិងទ្រាំទ្រឱ្យមែនទែនកុំឱ្យឈ្លើយ ។ ចំណែកពេលវេលាវិញ មិនមែនជាការកំរិតថា ត្រូវតែឱ្យត្រឹមកំណត់ប៉ុណ្ណោះឆ្នាំប៉ុណ្ណោះខែឡើយ ។ យើងតាំងចិត្តធ្វើបានប៉ុន្មានក៏យកប៉ុណ្ណោះទៅ ក៏ប៉ុន្តែក្នុងរវាងពេលកាន់ទុក្ខនោះ ត្រូវឱ្យមានការសង្រួមឱ្យបានបរិបូណ៌ ។ ឯស្ត្រីមេម៉ាយ កាលណាឈប់កាន់ទុក្ខគប្បីស្លៀកពាក់តែសំពត់អាវ ដែលមានពណ៌មិនឆើតឆាយ ដូចពណ៌ប្រផេះស្វាយខ្ចី-ខៀវខ្ចី-ពណ៌ដែក-ពណ៌ស្រគាំ ។ល។ នេះទើបសមរម្យ ។ លុះត្រាតែមានប្តីទៀត ទើបប្រើប្រាស់តាមរបៀបអ្នកមានប្តី ។

មួយទៀត ក្នុងរោងរបាំតូរ្យតន្ត្រីមានល្ខោនជាដើម នោះមិនមានការហាមប្រាមទេ ក៏ប៉ុន្តែបើយើងនៅក្នុងការទុក្ខហើយចូលទៅមើលរបាំ អ្នកទាំងពួងគេមើលមកហាក់ដូចជាឱ្យទើសភ្នែកគេ ឬឱ្យគេកើតទុក្ខអផ្សុកចិត្ត ដោយសារយើងមិនខាន មិនតែប៉ុណ្ណោះឡើយដូចជាត្រូវគេអញ្ជើញទៅក្នុងមង្គការអាពាហ៍ពិពាហ៍ ឬទៅទទួលលៀងភោជនាហារពិសារកំសាន្តនោះក៏ពុំគួរគប្បីទទួលអញ្ជើញគេឱ្យសោះ គួរតែតបតាមផ្លូវលិខិតសុំអភ័យទោសគេថា "យើងកំពុងមានកិច្ចជាប់នៅក្នុងត្រណមកាន់ទុក្ខ" ។ តែបើយើងយល់ថា កិច្ចនេះខានមិនបាន ត្រូវយើងលាកាន់ទុក្ខជាមុនឱ្យស្រេចនេះឥតទាស់ទេ ។

ការកាន់ទុក្ខនេះ មិនមែនមួយថ្ងៃកាន់ មួយថ្ងៃលានោះទេ បើកាន់ហើយ ត្រូវកាន់ឱ្យត្រឹមត្រូវតាមពេលកំរិត បើលាទុក្ខហើយត្រូវលាឱ្យរហូត ។

* *
*

មិត្រនឹងញាតិសាន

យើងជាមិត្រ ឬអ្នកនៅជិតខាងភូមិផងរបងជាមួយ គប្បីសម្តែងកាយវាចាចិត្ត ជួយទទួលចំណែកទុក្ខពាក់កណ្តាលអំពីកូន-ចៅ និងញាតិសា

លោហិតនៃសពនោះដែរ ។ ដូច្នេះគប្បីស្លៀកពាក់កុំឱ្យឆើតឆាយពេកឱ្យល្មមយ៉ាងកណ្ដាល ។

ពេលហែសពទៅរំលាយ ឬទៅបញ្ចុះ ស្រី១គប្បីស្លៀកសំពត់ខ្មៅខៀនពណ៌ខៀវ-ពណ៌ព្រីងទុំ-ព្រីងទុំក្រម៉ៅ (ពណ៌ដែក) ។ ពាក់អាវសពានាក្រមាស ឬក្រមាដែលមានពណ៌ស្រគាំ១ ដូចជាឋានសផ្កាខ្មៅ-ឋានខ្មៅផ្កាស ។

ប្រុស១គប្បីស្លៀកពាក់សសុទ្ធក៏បាន ពណ៌ស្រគាំ១ក៏បាន ។ ចងក្រវាត់ខ្មៅក៏បាន ឬក្រវាត់ពណ៌ស្រគាំ១ក៏បាន គឺថាកុំប្រើពណ៌ឆើតឆាយ ។ ស្បែកជើងពុំមានឱ្យទាស់ទេ ទោះពណ៌សក្ដី-ខ្មៅក្ដី-ក្រហមក្ដី-លឿងក្ដី តែបើឱ្យសមរម្យតាមរបៀបកាន់ទុក្ខ គួរប្រើស្បែកជើង-ស្រោមជើងស និងខ្មៅ ។ នេះហៅថាសម្ដែងកាយគោរពចំពោះសព និងអ្នកមានទុក្ខ ។

យើងបានដំណឹងថា មិត្រព្រៀងលានយើង មានទុក្ខដោយមរណសង្គ្រាម យើងក៏កើតមានចិត្តអាណិតដល់មិត្រព្រៀងលានយើង ឬមានចិត្តអាឡោះអាល័យដល់អ្នកស្លាប់ ដែលធ្លាប់កំសត់កម្រនឹងគ្នា ។ យើងក៏ម្នីម្នាទៅគួរសម នឹងក្រុមញាតិនៅគេហស្ថានសព នោះសម្លៀកបំពាក់ ក៏គប្បីស្លៀកពាក់ឱ្យគួរសមដូចមានពោលហើយខាងលើ ។

អ្នកទៅបុណ្យខ្មោច ហើយស្លៀកខោបារាំងពាក់តែអាវសឺមិសទទេ ឬមានអាវបើកកដែរ តែពុំចងក្រវាត់នេះពុំសមរម្យទេ បើប្រសិនជាយើងពាក់អាវកុតកត្រង់នោះប្រសើរជាង សមជាង ។

* *
*

អ្នកបួសមុខភ្លើង

អ្នកបួសមុខភ្លើង គប្បីរៀបខ្លួនប្រាណឱ្យបានស្រួលបួល ព្រោះអ្នកបួសនោះ ចេញមុខមាត់ឱ្យអ្នកផងឃើញបានរាល់គ្នាក្នុងចំណោម ។ បើជាស្បៀកសំឡយសំពត់ស ពាក់អាវកុតស ឬអាវចិនស ស្ពាយឈៀងក្រមាស សមរម្យណាស់ ។

ខ្ញុំរៀបរាប់យ៉ាងនេះ ព្រោះខ្ញុំបានឃើញច្រើនណាស់មកហើយ អាចារ្យបណ្តោយឱ្យតែអ្នកបួសមុខភ្លើងខ្លួនទទេនលតតពាក់អាវ ធ្វើបែបនេះមិនល្អមើលសោះ ។

* *
*

៣_សម្លៀកបំពាក់ក្នុងឱកាសរៀបមង្គលការអាពាហ៍ពិពាហ៍

****

រៀបមង្គលការអាពាហ៍ពិពាហ៍បុត្រធិតាឱ្យមានស្វាមីភរិយា ជាពិធីមួយរបស់មនុស្សគ្រប់ប្រទេសគ្រប់ជាតិ តែតែងតែធ្វើ ។ ព្រោះជាទម្លាប់ទំនៀម, សម្រាប់សំគាល់ឱ្យដឹងថា បុត្រធិតាដែលរៀបការជាគូស្រករនេះ ប្រកបដោយដំបូន្មាននៃមាតាបិតា គ្រូអាចារ្យ ចាស់ទុំ ក្នុងត្រកូលរៀង១ខ្លួន ។ តែការរៀបចំផ្សំកូនស្រី និងកូនប្រុសឱ្យជាប្ដីប្រពន្ធ មានរបៀប

ប្លែកៗគ្នាតាមជាតិតាមប្រទេស ។ កុំថាឡើយតែជាតិដទៃប្រទេសដទៃ សូម្បីតែជាតិមួយប្រទេសមួយផងគ្នា ខុសគ្នាតែខែត្រ និងស្រុកប៉ុណ្ណោះ របៀបរៀបចំមង្គលការក៏រមែងប្លែកអំពីគ្នាខ្លះៗដែរ ។

ក្នុងទីនេះ សូមសម្តែងតែអំពីសម្លៀកបំពាក់ក្នុងឱកាសរៀបមង្គលការអាពាហ៍ពិពាហ៍ :

១- សម្រាប់សាមីខ្លួនអ្នកការ ។

២- ភ្ញៀវគឺញាតិសាច់សាលោហិត ជិតឆ្ងាយព្រៀងលាន និងមិត្រសម្លាញ់ ។

បុរាណខ្មែរ សាមីខ្លួនមិនរាប់អានសោះ ពណ៌ស និងពណ៌ខ្មៅក្នុងឱកាសរៀបមង្គលការអាពាហ៍ពិពាហ៍ ។

សូមសង្កេតមើលចុះ សាមីខ្លួនអ្នកការមិនដែលស្លៀកពាក់សំពត់អាវខ្មៅ-សសោះឡើយ គេប្រើតែពណ៌លឿង និងក្រហមជាឯក ពណ៌ឯទៀតៗជាបន្ទាប់បន្សំ ។

ដូចជាសាមីខ្លួនកូនប្រុស ពេលស្តាប់ព្រះសង្ឃចំរើនព្រះពុទ្ធមន្តគេស្លៀកសំពត់សារបាប់ពាក់អាវសារបាប់ ។ បើរកសំបត់អាវសារបាប់មិនបាន គេស្លៀកសំពត់សូត្រពណ៌ផ្សេងៗ (ផាមួង) ពាក់អាវពណ៌ ឬអាវផ្កាមាស ។

ដល់ពេលសំពះទទួលស្លាពរ (ផ្ទឹម) គេពាក់អាវផាយព្រៃក្រហមពីលើអាវសារបាប់ទៅទៀត ឯអស់លោកដែលមានយសស័ក្តិជាមន្ត្រីធំក្តី

តូចក្តី អាវផាយព្រៃក្រហមនោះ មានប៉ាក់ឱនមាសជាផ្កាលើសាច់ព្រៃថែម ទៀត ។

សំពះស្ពាពរហើយផ្លាស់ស្លៀកសំពត់ផាមួងពណ៌ និងអាវកុត ឬអាវ ចិនពនិទៀតក៏បាន ។

ចំណែកសាមីខ្លួនស្រី ពេលស្តាប់ព្រះសង្ឃចំរើនព្រះពុទ្ធមន្តក្តី ព្រឹក ឡើងផ្ទឹមក្តី សម្លៀកបំពាក់គ្រឿងអលង្ការប្រើតែ១បែប ។

គេតែងខ្លួនស្លៀកពាក់តែសំពត់អាវពណ៌ជាជរាប អ្នកមានទ្រព្យ សម្បត្តិច្រើនគ្រប់ជាន់គ្រប់ថ្នាក់ គេតែងខ្លួនប្រាណដូចល្ខោនព្រះរាជទ្រព្យ (គឺដូចស្រីទេពធីតា ដែលយើងឃើញក្នុងគំនូរ ខុសគ្នាតែមិនពាក់មកុដ) ។ គេស្លៀកសំពត់សារបាប់ ឬសំពត់ល្បើកពាក់អាវទ្រនាប់ពណ៌ក្រហម លឿង ។ល។ ពាក់ស្បៃ ឬភួយប៉ាក់ឱន និងគ្រឿងអលង្ការផ្សេង១ថែម ទៀត ។

ចំណែកខាងអ្នកស្រែចំការ ដែលក្រខ្សត់ប្រដាប់តែងខ្លួនបែបដូច អធិប្បាយខាងលើនេះ គេស្លៀកសំពត់ផាមួង ឬហូល ពាក់អាវបំពង់វែង និងពានាផាហ៊ុមព្រៃពណ៌ផ្សេង១ ។

ដល់មកសម័យថ្មីនេះ អ្នកខ្លះផ្លាស់ប្តូរបែបផែនតែងខ្លួនក្នុងមង្គល ការ អាពាហ៍ពិពាហ៍នេះ ឱ្យងាយរៀបចំខ្លួនទៅវិញ ដោយហេតុពិបាករកខ្ចី ឬជួលគ្រឿងមកតែងខ្លួនដូចទេវតាពេក ក៏ចាត់ការដេរអាវបែបទំនើបថ្មី

តាមសម័យនិយម គឺអាវព្រៃពណ៌ផ្សេងៗ មានតម្លៃក៏គួរសមតាមធនធាន ហើយស្លៀកសំពត់សូត្រពណ៌តាមថ្ងៃ ។

ក្រៅពីបីពេលនេះ ក៏ដោះចេញស្លៀកពាក់តាមបែបតែងខ្លួនឱ្យស្អាតតាមធម្មតាវិញ ។

សោតឯអ្នកផ្លូវចៅមហាទៀត ដែលជាអ្នកនិយាយការ និងលោកមេបាចាស់ទុំត្រកូលរៀមច្បងខាងស្រី ក៏មានសម្លៀកបំពាក់ពណ៌ជាដរាប អ្នកមហាមានអាវផាយក្រហម ពាក់ជាយសស័ក្តិសមសម្រាប់មុខងារ ។

ដែលខ្ញុំរៀបរាប់បន្តិចនេះ គ្រាន់តែបញ្ជាក់ឱ្យឃើញថា ខ្មែរពីបុរាណរាប់អានសំពត់អាវពណ៌ ក្នុងឱកាសរៀបមង្គលការអាពាហ៍ពិពាហ៍ ។

* *
*

សម្លៀកបំពាក់ក្នុងឱកាសលៀងក្រយាហារ

ចំណែកខាងភ្ញៀវខ្មែរបុរាណក៏ប្រើពណ៌ដែរ តែមិនដូចសាមីខ្លួនអ្នកការទេ គេច្រើនស្លៀកពាក់ឱ្យសមរម្យ តាមកិច្ចដែលហៅថាជាមង្គល. ព្រោះពណ៌ទាំងឡាយក្រៅអំពីស និងខ្មៅ ទុកជាពណ៌ដែលបង្កើតឡើងនូវសិរី ។ បើគេពុំអាចជៀសឱ្យផុតពីស និងខ្មៅគេតែងតែចម្រុះលាយពណ៌ គេមិនស្លៀកពាក់សសុទ្ធទេ ដ្បិតពណ៌សជាពណ៌សម្រាប់កាន់ទុក្ខ ឯពណ៌ខ្មៅជាពណ៌ដែលមិនរាប់ចូលក្នុងមង្គល ។

ដូច្នេះបុរសគេច្រើនស្លៀកសំពត់ពណ៌ផ្សេងៗ និងពាក់អាវស ។ ស្រីៗ គេប្រើស្ទើរតែពណ៌ទាំងអស់ គឺស្លៀកខៀវ-ផាមួង-ហូល ។ល។ ពាក់អាវពណ៌លាត ពណ៌ផ្កា ទាំងក្រមាបង់កក៏មានពណ៌ មានផ្កាទៀតដែរ ។

ដល់អារ្យធម៌អឺរ៉ុបចូលមក យើងយកបែបផែនគេមកប្រើជាច្រើន តាមសម័យនិយម ។

ទាំងប្រុសទាំងស្រីឥតប្រកាន់ថា ពណ៌អ្វីឡើយ តែគេត្រូវស្លៀកពាក់ឱ្យត្រឹមត្រូវតាមរបៀបខ្លួន ដែលឱ្យសមជាទីគោរពដល់អ្នកសាមីខ្លួនដើមការ និងភ្ញៀវផងគ្នាគឺៈ

ក-បុរសបើរៀបខ្លួនតាមរបៀបខ្មែរ គេស្លៀកសំពត់ពាក់អាវកុតកត្រង់ ស្បែកជើង ស្រោមជើងខ្មៅ ឬពណ៌ផ្សេងៗ ។ បើគេពាក់អាវបើកក គេចងក្រវាត់ទៀតទើបសមល្អ មិនឈ្លើយ តែបើពាក់អាវបើកក ចងក្រវាត់ ជើងទទេក៏ឈ្លើយណាស់ដែរ ។ ត្រូវឱ្យមានគ្រប់ប្រដាប់ទើបល្អមើល មិនទើសភ្នែកអ្នកទាំងពួង ។

ខ-តាមរបៀបអឺរ៉ុប គេស្លៀកខោជើងវែង [១] (ខោជើងខ្លី លើក្បាលជង្គង់មិនសមរម្យទេ) អាវបិទក ស្បែកជើងស្រោមជើង ខោជើងវែងអាវបើកក ចងក្រវាត់ក៏បាន ។ តែបើពាក់អាវបើកក មិនចងក្រវាត់ជាការមិនល្អមើលដែរ ។

បើស្លៀកខោជើងវែង ហើយពាក់តែអាវទ្រនាប់ទទេ (Chemise) គ្មានអាវក្រៅ (បើកក) នោះចងក្រាវ៉ាត់ក្តី មិនចងក្រាវ៉ាត់ក្តី នឹងបានឈ្មោះថា មិនចុះរបៀប មិនមានគោរពដល់គ្នានឹងគ្នា ក្នុងឱកាសមង្គលការ ។

គ-អ្នកដែលស្គាល់របៀប គេមិនដែលរៀបខ្លួនឱ្យទាស់ទេ ។ ខ្លះគេស្លៀកពាក់ តាមសម្លៀកបំពាក់ធំផង ដែលហៅថា "តឺនុយដឺស្វារ៉េ" (tenue de soirée) ផង គឺខោសាក្លាតខ្មៅ អាវបើកកស-សឺមិសដៃវែង ណឺដ៏ខ្មៅ ស្បែកជើង-ស្រោមជើងខ្មៅ (នេះសម្រាប់លៀងធំ) ។

សូមចាំថា: ១-ស្បែកជើងសង្រែក មិនគប្បីប្រើប្រាស់ក្នុងឱកាសតែងខ្លួន ទៅទទួលលៀងភោជនាហារនោះសោះឡើយ ។ ត្រូវពាក់ស្បែកជើងដែលឃ្ជុបបាត់ជើង, ស្បែកខ្មៅភ្លឺរលើប ជាស្បែកជើងបែបសំខាន់ណាស់ សម្រាប់ពាក់ក្នុងពេលដែលរៀបខ្លួនតាមរបៀបសម្លៀកបំពាក់ "តឺនុយដឺស្វារ៉េ" (tenue de soire) ។

២-លោកអ្នកមានទុក្ខ កំពុងទ្រាំទ្រទុក្ខទាំងនោះ ដោយមានសម្លៀកបំពាក់សសុទ្ធ ឬខ្មៅសុទ្ធ (សម្រាប់ស្រី១) ពាក់ប៉ានដៃខ្មៅនៅដៃអាវខាងឆ្វេង ឬសំពត់ខ្មៅ១បន្ទះតូច [១] (បានអធិប្បាយហើយក្នុងសំលៀកបំពាក់កាន់ទុក្ខ) នៅផ្នត់ព្រលាត់អាវបើកក (សម្រាប់ប្រុស) ជាការសំគាល់ថា ខ្លួនអ្នកមានទុក្ខ នោះមិនត្រូវអញ្ជើញទៅក្នុងមង្គលការអាពាហ៍ពិពាហ៍ទេ ។ បើថាត្រូវទៅខានមិនបាន ត្រូវចេញពីត្រណមកាន់ទុក្ខ

សិនទើបគួរ ។ បើយើងមិនទាន់ចេញពីកាន់ទុក្ខទេ ត្រូវយើងឆ្លើយជាលាយលក្ខណ៍អក្សរទៅវិញតបនឹងសេចក្ដីអញ្ជើញថា "យើងនៅក្នុងកំឡុងកាន់ទុក្ខទៅពុំបានទេ" ។

មិនតែក្នុងឱកាសមង្គលការទេ សូម្បីតែគេអញ្ជើញលៀងកំសាន្តសប្បាយ លោក-អ្នកកាន់ទុក្ខក៏អញ្ជើញទៅពុំគួរដែរ ព្រោះយើងនឹងស្ដាប់ច្រៀង-ភ្លេង-មើលល្ខោន ឬច្រៀងរាំដោយខ្លួនឯងក្ដី សញ្ញាដែលសំគាល់ទុក្ខនោះ ត្រឡប់ទៅជាក្លែងទៅវិញ ។

* *
*

៤-សម្លៀកបំពាក់ធ្វើការងារ

ពេលដែលទៅបំពេញកិច្ចការរាជការ នៅមន្ទីរស្ដីការនានានោះ បណ្ដាខ្ញុំរាជការធំ-តូចទាំងឡាយ គប្បីស្លៀកពាក់ឱ្យសមរម្យ ដើម្បីឱ្យប្រជារាស្ត្រអាចស្គាល់បានថា ជាមន្ត្រីដោយឫកពា និងដោយសម្លៀកបំពាក់ដ៏ស្អាតបាតត្រឹមត្រូវ ។ នៅក្នុងមន្ទីរស្ដីការនីមួយៗ បើអស់លោកស្លៀកពាក់មានរបៀបរៀបរយល្អ នោះជនដទៃដែលគេចូលទៅ គេរមែងមានសេចក្ដីកោតញញើត ដោយឃើញរបៀបរៀបចំទីកន្លែងធ្វើការ និងរបៀបរៀបចំខ្លួនប្រាណសមរម្យល្អ ។

បើយើងមានការចង់ទៅជួបនឹងលោកណាមួយ ដែលមានយសសក្តិខ្ពស់ជាងយើង នោះយើងគប្បីរៀបចំសម្លៀកបំពាក់ឱ្យបានសមរម្យ គឺថា បើតែងខ្លួនជាខ្មែរក្តី ជាបារាំងក្តី ក៏ត្រូវតែឱ្យមានសណ្ដាប់ធ្នាប់ជាដរាប ។

ឧបមាថា: យើងចង់ទៅជួបនឹងលោករដ្ឋមន្ត្រី ឬចៅហ្វាយខេត្ត ឬចាងហ្វាងសាលា ឬនាយក្រុមណាមួយ ។ល។ ដោយមានការរាជការ ឬការផ្ទាល់ខ្លួន នោះត្រូវតែយើងស្លៀកពាក់ឱ្យត្រឹមត្រូវ ។ ចំណែកលោកជាធំវិញ យើងមិនត្រូវរិះគន់លោកទេ ក្នុងពេលដែលលោកឈប់សម្រាកនៅផ្ទះ ព្រោះលោកពុំអាចជ្រាបបានមុនថា យើងទៅជួបនឹងលោក ។ ចុះបើក្នុងពេលធ្វើការវិញ លោកក៏គង់រៀបចំខ្លួនប្រាណឱ្យបានត្រឹមត្រូវ រាល់ពេលវេលាដែរ ដោយលោកមានការប្រយ័ត្ន ក្រែងមានភ្ញៀវពន្លឺចូលមកជួប ។

* *
*

៥_សម្លៀកបំពាក់ដើរកំសាន្ត

ដែលហៅថាដើរកំសាន្ត គឺយើងដើរលំហើយខ្លួន ដើរយកខ្យល់អាកាសតាមមាត់ទន្លេ មាត់ស្ទឹង មាត់បឹង មាត់ព្រែក សួនផ្កា ឬទីវាលឯណាមួយ ។ល។ ក្រោយពេលដែលយើងធ្វើការហត់នឿយព្រួយចិត្ត ព្រួយគំនិត

ដោយហេតុផ្សេងៗ ។ យើងដើរទៅលេងទីនោះ ឬអង្គុយសម្រាកកម្លាំង ឬឈរមើលទឹក និងព្រៃព្រឹក្សាបុប្ផាលតាវល្លិ៍ ដែលប្រកបដោយពណ៌ល្អមើល ទាំងមានក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់ ។ វត្ថុទាំងនេះជាគ្រឿងលំហែទុក្ខ សម្រាប់បំភ្លេចទុក្ខ បំភ្លេចសេចក្ដីនឿយព្រួយ បំភ្លេចការកង្វល់ទាំងឡាយ ទាំងពួងបានមួយគ្រាៗ ។

មិនតែប៉ុណ្ណោះទេ អ្នកដែលមានជម្ងឺឈឺស្កាំងស្កម ដូចជាអ្នកឈឺសួតជាដើម ក៏ត្រូវដើរទៅផ្លាស់អាកាសម្ដងៗដែរ តាមតម្រាវេជ្ជសាស្ត្រ ដែលលោកបានកំរិតទុកមក ។

តទៅទៀត នៅបន្ទាប់ពីការនឿយហត់ បន្ទាប់ពីពេលដើរលេង សម្រាកកម្លាំងកាយ និងគំនិត មានការចង់បរិភោគចំណីអាហារដ៏មានឱជារសឆ្ងាញ់ពិសា និងបានចំរើនកម្លាំងប្រកបការតទៅ ។ នោះត្រូវយើងស្វែងរកភោជនាគារ (ផ្ទះលក់បាយ) ណាដែលមានឈ្មោះល្បីខាងធ្វើម្ហូបចំណីគ្រប់បែបគ្រប់យ៉ាងអាស្រ័យ ។

ដំណើរកំសាន្តរបស់យើងទាំងនេះ ក៏ជាការសម្ដែងឬកពារចំពោះមុខមហាជនទាំងឡាយ ទាំងពួង ។ អ្នកទាំងពួងក៏មានការដើរលេងដូចៗគ្នា ក្នុងពេលត្រូវគ្នា ។ ដូច្នេះយើងទាំងអស់គ្នាគប្បីស្លៀកពាក់ឱ្យសមរម្យ ឱ្យជាទីគោរពដល់គ្នានឹងគ្នាទៅវិញទៅមក ព្រោះបើស្លៀកពាក់មិនសមរម្យនឹងរាប់ថា ជាសុភាពរៀបរយក៏ពុំបាន ទាំងឱ្យរំខានដល់មិត្តភក្ដិដែលជួបប្រទះគ្នានៅទីនោះៗផង ។

ឧបមា ដូចមានមិត្រ៣នាក់ កំពុងសន្ទនាគ្នានៅក្នុងសួន១កន្លែង ។ អ្នកទាំងនេះស្លៀកពាក់ចុះបែបផែន តាមអារ្យធម៌សម័យនិយម សមរម្យ ជាអ្នកមានឫកសុភាពខ្ពង់ខ្ពស់ ហើយមានម្នាក់ទៀត ដើរមកទីនោះដែរ តែស្លៀក "សារុង" ពាក់ "អាវកាក់" "បង់កក្រមាពញាក់" មកឈប់ឈរ និយាយផង យ៉ាងនេះឃើញថា មិនសមរម្យមិនល្អមើលដល់ភ្នែកអ្នកដទៃ ដែលគេមករកកន្លែងអាស្រ័យសម្រាកសម្រាន្ត កំសាន្តចិត្តដូចយើងដែរ ។

នេះហើយ ឃើញថាក្នុងពេលដើរកំសាន្តសប្បាយ ក៏ត្រូវស្លៀកពាក់ឱ្យត្រឹមត្រូវ ទើបមិនទើសភ្នែកគេឯង ទាំងជនអារ្យបរទេស ក៏គេមានពាក្យសរសើរដល់ជាតិដល់ប្រទេសយើងពុំខាន ។ បើពុំធ្វើដូច្នោះទេ នឹងមានពាក្យគេរិះគន់ថា ប្រទេសយើងនេះ មានពលរដ្ឋនៅល្ងង់ខ្លៅច្រើនណាស់ តាំងតែអំពីសម្លៀកបំពាក់ឡើងទៅ ។

ប្រមូលសេចក្ដីទៅ ឃើញថាសម្លៀកបំពាក់ដើរលេង ដើរមើលបុណ្យផ្សេងៗ ប្រុសក្ដី ស្រីក្ដី គប្បីតែតែងខ្លួនឱ្យល្អមើល ឱ្យត្រូវភ្នែកអ្នកទាំងពួងផង គឺថាបើប្រសិនជាយើងរៀបខ្លួនតាមជនអារ្យប្រទេស នោះឃើញថា រុងរឿងល្អក្នុងប្រទេសយើង ។

ប្រុសស្លៀកខោជើងវែង ស្បែកជើង ស្រោមជើង ពាក់អាវសឺមិសដៃវែង ឬដៃខ្លី ចងក្រាវ៉ាត់ ឬឥតក្រាវ៉ាត់ក៏បាន ឬពាក់អាវហោប៉ៅ៤ដៃខ្លីក៏បាន ។ ស្ត្រីក៏តែងខ្លួនតាមសម័យថ្មី មានពាក់អាវបែបទំនើបប្លែកគ្នា

តាមរចនា ។ សូម្បីតែកូនចៅតូចៗ ដែលទើបនឹងចេះដើរចេះរត់ក៏ត្រូវតែរៀបចំខ្លួនប្រាណវាឱ្យសមតាមសម័យ ឱ្យបានស្អាតបាតល្អដែរ ។

ដូចជាដើរមើលបុណ្យផ្សេងៗ មានបុណ្យតាំងតុ ឬអុំទូកជាដើមនោះ គួរតែងខ្លួនប្រាណឱ្យល្អបន្តិចឡើងទៀត គឺល្អដោយសាច់សំពត់និងពណ៌សំពត់ដែលយកមកកាត់អាវ ។

* *
*

៦_សម្លៀកបំពាក់ទៅលេងផ្ទះបងប្អូន ឬមិត្រសម្លាញ់

បងប្អូន និងមិត្រសម្លាញ់ ជាមនុស្សស្និទ្ធជិតនឹងគ្នា ដោយមេត្រីចិត្ត ដោយសេចក្ដីរាប់អាន មានការឈឺឆ្អាល ឬទឹករលីកគ្នាជួយធុរៈគ្នាទៅវិញទៅមក ។

ដូច្នេះ កាលគ្រាទៅលេងនឹងគ្នាសួរសុខទុក្ខក្ដី ជួយខ្វាយខ្វល់ក្នុងកិច្ចការផ្សេងៗក្ដី យើងគប្បីរៀបចំសម្លៀកបំពាក់ឱ្យសមរម្យល្មមតាមកាលវេលា ។

ប្រៀបដូច:

ទៅលេងសប្បាយដោយទឹករលីក ឬជួយធុរៈ នោះគប្បីស្លៀកពាក់យ៉ាងល្មមគឺបាន ។

ប្រុសស្លៀកខោជើងវែង អាវសឺមិសមានក្រាវ៉ាត់ក៏បាន ឥតក្រាវ៉ាត់ក៏បាន ស្បែកជើងសង្រែកក៏បាន ឬមួយខោចិនអាវចិន ស្បែកជើងផ្ទាត់ក៏បាន ។ ស្លៀកពាក់យ៉ាងនេះ ដោយស្និទ្ធស្នាលនេះ១ ដោយឱ្យងាយជួយចាត់ចែងការទាំងឡាយមានលើកដាក់ជាដើមនេះ ១ ។

បើពុំនោះសោត យើងស្លៀកពាក់យ៉ាងស្អាតល្អត្រឹមត្រូវដូចជាទៅរកលោកអ្នកធំនោះ ក៏គួរដែរ តែយើងពុំអាចនឹងជួយធ្វើការងារក្នុងគ្រាគេមានធុរៈលើកដាក់នោះបានឡើយ ព្រោះសម្លៀកបំពាក់យើងស្អាតល្អណាស់មិនគួរនឹងជួយធ្វើការគេទេ ។

ចំណែកស្ត្រីវិញ ក៏គួរស្លៀកពាក់ឱ្យសមល្មមដូចមានអធិប្បាយសម្រាប់បុរសខាងលើនេះដែរ ។

* *
*

៧_សម្លៀកបំពាក់នៅផ្ទះ

អ្នកផ្ទះត្រូវមានរបៀប ៣ យ៉ាងៈ

១-បើភ្ញៀវនោះ មិនជាញាតិសាលោហិតទេ មិនជាមិត្រសម្លាញ់ទេ ជាមនុស្សទើបនឹងស្គាល់គ្នាថ្មីៗ ជាមន្ត្រីក្តី ជាពាណិជ្ជក្តី ជាជនសាមញ្ញក្តី ។ល។ ហើយបានឱ្យដំណឹងមុនថា នឹងមកលេង ដើម្បីសេចក្តីសមគួរ ឬដើម្បីចងមេត្រីភាពទៅថ្ងៃមុខ នោះអ្នកផ្ទះគប្បីរៀបចំខ្លួនប្រាណឱ្យបានសមរម្យបំរុងខ្លួនចាំទទួលភ្ញៀវ ។

២-បើភ្ញៀវនោះ មិនបានឱ្យដំណើងមុនទេ តែលោកជាក្សត្រិយ៍ ឬជាមន្ត្រីធំក្តី-តូចក្តី ធ្លាប់មានសេចក្តីរាប់អានមកជាយូរហើយ ។ អ្នកផ្ទះបានឃើញស្តេច-អញ្ជើញមកពីចម្ងាយ ឬឃើងនៅក្នុងផ្ទះ ហើយក្មេងបំរើមកប្រាប់ថា ព្រះអង្គម្ចាស់នោះ-លោកនោះ-អ្នកនោះ ស្តេចអញ្ជើញមក អ្នកផ្ទះត្រូវវាសរវៃស្លៀកពាក់ឱ្យសមរម្យចេញទទួល គឺត្រូវផ្លាស់សារុងចេញ ស្លៀកខោពាក់អាវឡើងវិញ (១) (ត្រង់នេះ ក្រែងនៅផ្ទះ ស្លៀកសារុង ខ្លួនទទេ ។ យើងស្លៀកត្រឹមខោចិន អាវចិនល្មម ឬខោអាវភិស្សម៉ាក៏បាន) ។

៣-បើភ្ញៀវជាបងប្អូនសាច់សារលោហិត ជាមិត្រស្និទ្ធស្នាលធ្លាប់ឡើងចុះយប់ថ្ងៃ អាស្រ័យគ្នាជិតដិតឥតប្រកាន់ នោះអ្នកផ្ទះគប្បីពាក់តែអាវក៏បាន (២) (ត្រង់នេះអាវអ្វីក៏បាន កុំឱ្យតែខ្លួនទទេ) ។

ចាំ-ការទទួលភ្ញៀវខ្លួនទទេ មិនត្រូវទំនងសោះ មិនល្អមើលសោះ ព្រោះហាក់ដូចជាមើលងាយភ្ញៀវ ។ ដែលថាខ្លួនទទេត្រង់នេះ សំដៅចំពោះរូបបុរសទេ ក៏ប៉ុន្តែបើប្រសិនជាស្ត្រីទទួលភ្ញៀវប្រុស ពាក់តែអាវទ្រនាប់គ្មានអាវក្រៅ ឬគ្មានដណ្តប់ក្រមា ក៏នឹងត្រូវការនិន្ទាអំពីភ្ញៀវខ្លះមិនខាន តែបើមានអាវគ្រប់គ្រាន់ហើយនោះមិនចាំ បាច់ដណ្តប់ក្រមាថែមទៀតទេ ។

* *
*

សម្លៀកបំពាក់ជាផ្លូវការ

សម្លៀកបំពាក់ជាផ្លូវការ មានរបៀបផ្សេងៗគ្នា ។ តែសូមញែកខាងដើមត្រឹម២បែបសិនចុះ គឺរបៀបទាហាន១ របៀបស៊ីវិល១ ។

ក-របៀបទាហាន មិនបាច់អធិប្បាយក្នុងទីនេះទេ ព្រោះមានបញ្ហាខាងទាហានជាខ្នាតវិន័យ ត្រឹមត្រូវរបស់គេស្រាប់ទៅហើយ ។

ខ-ឯរបៀបស៊ីវិលមានច្រើនបែប ដូចមានពោលតទៅនេះ :

១-ឡើងគាល់ព្រះមហាក្សត្រិយ៍ម្ចាស់ផែនដី ក្នុងព្រះបរមរាជវាំងមានការផ្ទាល់ខ្លួន ឬការរាជការ នោះមន្ត្រីធំក្ដី-តូចក្ដី ប្រជាជនទាំងឡាយក្ដីត្រូវស្លៀកពាក់ឱ្យត្រឹមត្រូវសមរម្យជាទីគោរពពេញបរិបូណ៌គឺថា:

បើរៀបខ្លួនតាមរបៀបខ្មែរ នោះចំណែកមន្ត្រីត្រូវស្លៀកសំពត់អាវកុតសកត្រង់ ឡេវត្រាមកុដមាស ឬប្រាក់ តាមឋានន្តរស័ក្តិរបស់ខ្លួនស្បែកជើងខ្មៅ ស្រោមជើងវែងខ្មៅ ។

ចុះបើជារាស្ត្រសាមញ្ញវិញ អ្នកមានធនធាន អាចនឹងស្លៀកពាក់បានដូចគ្នា តែមិនត្រូវប្រើឡេវត្រាមកុដទេ (១) (យើងមានធនធានហើយនឹងប្រើឡេវមាស-ប្រាក់បានតាមចិត្ត កុំតែលែវត្រាមកុដ) ។ អាវកុតទៀតក៏ត្រូវកាត់ជារបៀបអាវធម្មតា កុំប្រើអាវមានឡេវចង្កេះដូចមន្ត្រីឡើយ ។

អ្នកដែលក្រខ្សត់ ក៏គប្បីស្លៀកសំពត់ពាក់អាវកុត ឬអាវមិនដើងទទេក៏បាន សន្ដោសដោយទ័លក្រ ។ បើស្លៀកពាក់យ៉ាងនេះស្អាតបាតហើយនោះ មិនត្រូវយកក្រមាពញ្ញក់មកវាត់ស្ពាយឈៀង ឬក្រវាត់ពីលើអាវទៀតទេ នាំឱ្យរយីករយាកឥតប្រយោជន៍ ។

២-បើក្រាបបង្គំគាល់ក្រៅព្រះបរមរាជវាំងវិញ ដូចជាក្នុងពេលព្រះមហាក្សត្រិយ៍ ស្ដេចយាងទៅវត្ត ឬតាមអាណាខែត្រ តាមតំបន់ជនបទជិតឆ្ងាយ, មន្ត្រីខែត្រ ស្រុក-ឃុំអាចារ្យវត្ត និងឧបាសក-ឧបាសិកាអ្នកស្រុកទាំងប្រុស-ស្រី គប្បីស្លៀកពាក់ឱ្យស្អាតបាតត្រឹមត្រូវដូចបានអធិប្បាយខាងលើនេះ ។ (ហាមផ្ដាច់មិនឱ្យស្លៀកសារុង, ស្លៀកក្រមា, ពាក់មួក, ទទូក្រមា, ឈរក្រពាត់ដៃ, ច្រត់ចង្កេះ, បៀមខ្សៀ ឬបារី ឬលែងខ្លួនទទេឈរទទួលព្រះមហាក្សត្រិយ៍ឡើយ) ។

៣-សម្លៀកបំពាក់ស្ត្រី ដែលចូលគាល់ព្រះមហាក្សត្រិយ៍នោះត្រូវស្លៀកសំពត់ចងក្បិន ពានាក្រមាពីលើអាវទៀត ធ្វើដូច្នេះឈ្មោះថា ជាសម្លៀកបំពាក់ពេញទី ជាទីគោរពព្រះមហាក្សត្រិយ៍ ។ តែដល់មកអារ្យធម៌សម័យនេះ គេច្រើនស្លៀកសំពត់-ពាក់អាវម៉ូតមានពណ៌ផ្សេងៗឥតប្រើក្រមាពានាទៅវិញ ។

សូមកុំភ្លេច: យើងជាពលរដ្ឋត្រូវគោរពព្រះប្រិយមហាក្សត្រិយ៍យើងឱ្យបរិបូណ៌ តាមប្រវេណីពីបុរាណកាល ដូច្នេះយើងមិនត្រូវរៀបចំខ្លួនប្រាណឱ្យឈ្លើយឡើយ ។ អ្នកស្លៀកខោខ្លីលើក្បាលជង្គង់ បង់កក្រមា ខ្លួន

ទទេស្បែកសារុង '១' (សារុងហាមផ្ដាច់មិនឱ្យស្លៀកចូលព្រះបរមរាជវាំង ឬស្លៀកចូលវត្ត ។ ម្យ៉ាងទៀតប្រទេសយើងបានឯករាជ្យហើយ មិនត្រូវស្លៀកសារុងដើរផ្សារចេញមុខមាត់ទេ ព្រោះសារុងគេសម្រាប់តែស្លៀកនៅផ្ទះ ឬស្លៀកដេកប៉ុណ្ណោះ) ស្លៀកក្រមាលយឆាយយ៉ាងនេះ មិនត្រូវចូល គាល់ម្ចាស់ផែនដីទេ ។

ដោយហោចណាស់ទៅ

ក៏ត្រូវស្លៀកត្រឹមខោជើងអាវជើង '១' (ខោអាវនេះស្លៀកពាក់ចូលគាល់ក្នុងព្រះបរមរាជវាំងមិនបានទេ) ទៅចុះ ដោយផាខ្លួនក្រឡុត់ទុគិតពេកហោស់ ។ ត្រូវបិទឡេវអាវឱ្យគ្រប់ទាំងអស់ សូម្បីតែឡេវកក៏ពុំត្រូវភ្លេចបិទឱ្យសោះ ។ ការមិនបិទឡេវអាវជាបទព្រហើន១ ដែលគេទុកជាអ្នកមិនស្គាល់ច្បាប់ខុសត្រូវក្នុងគោរវកិច្ច ។

៤ បើរៀបចំខ្លួនប្រាលេ តាមរបៀបអឺរ៉ុបវិញ នោះក៏ត្រូវធ្វើតាមគន្លងច្បាប់ទម្លាប់គេឱ្យបរិបូណ៌ដែរគឺថា:

ស្លៀកខោជើងវែង អាវបើកក ចងក្រាវ៉ាត់-ស្បែកជើង ស្រោមជើង.

សូមកុំភ្លេច ពាក់អាវបើកកមិនចង់ក្រាវ៉ាត់ ពាក់ស្បែកជើងសង្រែក មិនត្រូវហ៊ានឡើងគាល់ព្រះរាជាទេ នៅទីណាក៏ដោយលើកមួយតែយើងដើរទៅប្រទះស្ដេចយាងព្រះរាជដំណើរតាមផ្លូវ ។

សម្លៀកបំពាក់សម្រាប់ឡើងគាល់ព្រះមហាក្សត្រិយ៍ ជារបៀបស៊ីវិល ត្រូវរាប់បញ្ចូលជាផ្លូវការទាំងអស់ ព្រោះយើងត្រូវតែស្លៀកពាក់ឱ្យត្រឹមត្រូវនៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ។

* *
*

សម្លៀកបំពាក់ក្នុងព្រះរាជពិធីផ្សេងៗ ឬក្នុងពិធីណាមួយនៃព្រះរាជរដ្ឋាភិបាល

ក្នុងព្រះរាជពិធីក្ដី ក្នុងពិធីនៃរដ្ឋាភិបាលក្ដី លោកអ្នកមានបណ្ដាស័ក្តិត្រូវតែងខ្លួនតាមឋានន្តរស័ក្តិរបស់ខ្លួន និងតាមសេចក្តីអញ្ជើញ ឬតាមសេចក្តីបង្គាប់ដែលមានក្នុងកម្មវិធី សំដែងត្រង់សម្លៀកបំពាក់ ។

ឧបមា. ដូចឡើងគាល់ព្រះរាជាជាម្ចាស់ជីវិតលើត្បូង នៅព្រះទីនាំងទេវាវិនិច្ឆ័យ ក្នុងឱកាសព្រះរាជពិធីទ្វាទសមាសណាមួយ ហើយមានបង្គាប់ពីក្រុមព្រះរាជមន្ទីរក្តី ក្រុមព្រះរាជាយុត្តកៈក្តី ថាឱ្យពាក់គ្រឿងឥស្សរិយយសព្យួរ ហើយអស់លោកត្រឡប់ជាពាក់រុយបង់ទទេទៅវិញ (barrette) នេះហៅថា ចូលក្នុងបទល្មើស១ ។

ដូច្នេះ សម្លៀកបំពាក់ ត្រូវប្រយ័ត្នកុំឱ្យខ្វះឱ្យសោះ ។ បើយើងបដិបត្តិតាមសេចក្ដីបង្គាប់ ឬសេចក្ដីអញ្ជើញពុំបានទេ នោះគួរគប្បីតែសូមទោស កុំទៅល្អជាង ដើម្បីចៀសវាងសេចក្ដីរិះគន់ ឬសេចក្ដីបន្ទោសអំពីនាយចៅហ្វាយ ។

ព្រះរាជពិធី ក្នុងព្រះបរមរាជវាំង ក្រុមព្រះរាជមន្ទីរ មានអំណាចឃាត់លោកអ្នកស្លៀកពាក់ខុសពីកម្មវិធីមិនឱ្យឡើងគាល់បាន ។

មិនតែក្នុងព្រះរាជពិធីទេ សូម្បីតែពិធីណាមួយដែលរដ្ឋាភិបាលធ្វើហើយបានជូនដំណឹងថា សម្លៀកបំពាក់បែបនេះបែបនោះ លោកអ្នកបានទទួលសេចក្ដីអញ្ជើញ ក៏ត្រូវបដិបត្តិតាមជាដរាបដែរ ។

ចំណែកសាមញ្ញជនដែលគ្មានឋានន្តរសក្តិ ត្រូវស្លៀកពាក់តាមធម្មតា គឺឱ្យចុះបែបផែនសម័យនិយម ។

បើតែងជាខ្មែរគឺសំពត់-អាវកុតកត្រង់-ស្បែកជើង-ស្រោមជើង ។

បើតែងជាបារាំង-គឺខោវែង-អាវបើកក ចងក្រាវ៉ាត់-ស្បែកជើង-ស្រោមជើង ។

កុំភ្លេចថា ស្បែកជើងសង្រែកមិនត្រូវពាក់ក្នុងឱកាសធ្វើពិធីជប់លៀង ឬមង្គលការអ្វីមួយជាដាច់ខាត ។

សម្រាប់ស្ត្រី សំពត់ចងក្បិន ឬខៀន ជាបែបផែនរបស់ខ្មែរពីដើមមក ដែលគេតែងរាប់អានក្នុងពេលប្រជុំធំ ។ ដល់មានបែបបរទេសចូល

មកទៀត ក៏ប្រែក្លាយដោយនិយមទៅ ។ ខ្លះស្លៀកហូលសំឡុយ ពាក់អាវទំនើបថ្មី ខ្លះស្លៀកពណ៌ផ្សេងៗ ពាក់អាវទំនើបថ្មី ពាក់ស្បែកជើងក៏ទំនើបដែរ ។ តែងខ្លួនបែបនេះ ក៏សមរម្យល្អដែរ ។ តែពេលប្រជុំធំដូចបានពោលហើយខាងលើនេះ ដែលបណ្ដាអស់លោកប្រុស ៗ ស្លៀកសំពត់ពណ៌ ស្រីគប្បីប្រើ ពណ៌ដែរ កុំស្លៀកសំពត់សំឡុយខ្មៅ ។

* *
*

សម្លៀកបំពាក់តាមរដូវ

នឹងរៀបរាប់អំពីសម្លៀកបំពាក់តាមរដូវនេះបន្តិចទៅទៀត ដើម្បីវែកញែកឱ្យភ្លឺច្បាស់ អំពីគំនិតជាងតម្បាញ ដែលត្បាញសំពត់ឱ្យយើងប្រើប្រាស់សព្វថ្ងៃនេះ ។

គេធ្វើសំពត់មានក្រាស់មានស្ដើង សម្រាប់កុំឱ្យអ្នកទាំងឡាយខ្វះខាតចាត់ចែងដេរខោអាវ ឱ្យបានគ្រប់គ្រាន់តាមរដូវក្ដៅ-ត្រជាក់ ឬរងា ។

រដូវទាំងឡាយក្នុងឆ្នាំនីមួយៗ រមែងបង្កើតជាភោគផ្សេងៗ ដល់មនុស្ស ដោយអាកាសប្រែប្រួលនៅវេលាផ្លាស់រដូវ ។ ហេតុនេះហើយបានជាយើងត្រូវបិទបាំងរូបកាយការពារនឹងរដូវក្ដៅត្រជាក់ កុំឱ្យឈឺចាប់បាន

ដោយងាយ មកពីការធ្វេសប្រហែស ឬដោយយើងមិនស្គាល់តម្រាអនាម័យ ។

សំពត់ក្រាស់ៗ មានពណ៌ខ្មៅជាដើម ដូចជាសំពត់សាក្លាតជាដើម គេសម្រាប់កាត់ខោអាវប្រើប្រាស់តែក្នុងរដូវត្រជាក់ និងរដូវរងា មិនចំពោះតែប្រុសទេ ស្រីៗក៏ប្រើបានដូចគ្នាទាំងអស់ ។

ឯសំពត់ស្តើង ពណ៌អ្វីក៏ដោយ គេសម្រាប់តែស្រីៗ ប្រើធ្វើអាវក្នុងរដូវក្តៅ (តែបើបុរសចង់ប្រើកាត់ជាអាវសឺមិស ឬអាវចិនក៏បានខ្លះដែរ) ។

ត្រង់នេះ ពុំបាច់អធិប្បាយឱ្យពិស្តាទេ គ្រាន់តែឱ្យយល់បានថា កុំពាក់អាវសាក្លាតក្នុងរដូវក្តៅ វាត្រឡប់ជាបានឈឺចាប់ទៅវិញ ដោយបែកញើសជាខ្លាំងបណ្តាលឱ្យទៅជាខ្យល់ចាប់វិលមុខផង ។ល។

ចុះបើរដូវរងាវិញ យើងខំប្រឹងទ្រាំរងា ដោយសារតែចង់ពាក់អាវស្តើង ដែលទើបនឹងកាត់ថ្មីនោះៗក៏គង់នឹងបង្កើតទៅជាជម្ងឺអ្វីមួយមិនខាន ដោយហេតុបណ្តាលអំពីអាកាសត្រជាក់ ។ មិនតែប៉ុណ្ណោះទេ ស្រីខ្លះពាក់អាវស្តើងគ្មានដៃ រងាខ្លាំងពេកស្ទូដណ្តប់ភួយដើរ ចុះបើយើងប្រើអាវក្រាស់មានដៃវែងមិនរវល់ទាំងគ្រលំភួយ១ជាន់ទៀត នោះវាមិនស្រួលជាងយើងពាក់អាវស្តើងដៃខ្លីដណ្តប់ភួយឬ ?

មួយទៀត. ប្រទេសកម្ពុជាយើងនេះ ជាប្រទេសក្តៅ ដូច្នេះអាវពណ៌ខ្មៅមិនគប្បីប្រើប្រាស់សោះឡើយ ព្រោះក្បួនវិទ្យាសាស្ត្រ (Sciences)

លោកអ្នកប្រាជ្ញបានអធិប្បាយពន្យល់ថា ពណ៌ខ្មៅអាចស្រូបយកកំដៅព្រះអាទិត្យ បានសេចក្ដីថា បើយើងពាក់អាវខ្មៅដើរហាលថ្ងៃនោះកំដៅព្រះអាទិត្យអាចចូលកាត់សាច់សំពត់ទៅដល់សាច់យើងបាន ហើយបើក្ដៅខ្លាំង យើងនឹងឈឺចាប់មិនខាន ។ ហេតុនេះហើយបានជាគេប្រើអាវខ្មៅតែក្នុងរដូវរងា ។ ក្នុងរដូវឯទៀត ត្រូវប្រើតែបណ៌ស ឬពណ៌ផ្សេងៗដែលមានសម្បុរខុសពីពណ៌ខ្មៅ ។

* *
*

សារុង

សារុងជាសំពត់ស្លៀក១បែប របស់ជនជាតិចាម-ជ្វា-ភូមា ។ ខ្មែរយើងយកមកប្រើគ្រាន់តែស្លៀកនៅផ្ទះទេ ព្រោះសារុងមិនជាសម្លៀកសមរម្យ របស់ខ្មែរទេ ។ ហេតុនេះ ខ្មែរយើងស្លៀកសារុងបានតែនៅផ្ទះ មិនត្រូវស្លៀកដើរចេញក្រៅទៅតាមថ្នល់ ទៅផ្សារ ទៅមើលបុណ្យ ទៅផ្ទះអ្នកដទៃ ឬទៅវត្តឡើយ ។

* *
*

ក្រមាពព្លាក់

ក្រមាពព្លាក់ជាគូនឹងសារុង ។ យើងប្រើក្រមាពព្លាក់សម្រាប់តែស្លៀកងូតទឹក ឬស្លៀកនៅផ្ទះធ្វើការងារបន្តិចបន្តួចក្នុងរបងផ្ទះប៉ុណ្ណោះ ។ ដូច្នេះ ក្រមាពព្លាក់ មិនសម្រាប់ស្លៀកដើរតាមថ្នល់ ឬដណ្ដប់ បង់កទៅបុណ្យទានឬទៅផ្ទះគេទេ ។ ឯក្រមាអន្លូញសូត្រប្រើដណ្ដប់ ឬបង់កដើរចេញទៅក្រៅមិនមានទាស់ តែបើមានពណ៌ក្រឡាឆើតឆាយ ក៏ពុំសមនឹងប្រើប្រាស់ក្នុងពិធីធ្វើឈាបនកិច្ចឡើយ ។

* *
*

ពណ៌សំពត់ស្លៀកតម្រូវតាមថ្ងៃ

ពេលគេចងពាក្យកាព្យទុកមកនេះ

អាទិត្យក្រហមខ្ចីឬចាស់ ចន្ទផ្លាស់លឿងទុំស្វាយ អង្គារ
ថ្ងៃពុធស៊ុលៀបសមសោភា ព្រហស្បតិ៍ជាបៃតងត្រួយចេកខ្ចី ។
ពណ៌ខៀវក្រមៀវប្រើថ្ងៃសុក្រ ពណ៌នីលព្រីលទុកសៅរ៍សិរី (ព្រីងទុំ)
តែងខ្លួនតាមក្បួនលោកស្រដី ចំរើនសិរីជ័យជោគអើយ ! ។

* *
*

សក់ ពុកមាត់ ពុកចង្កា ក្រចក

ក្រៅពីសម្លៀកបំពាក់ យើងត្រូវមានកិច្ចសំអាតខ្លួនជាប់ជាមួយផង ។

ក្នុងឱកាសបុណ្យក្តី ពិធីអ្វីមួយក្តី ប្រជុំជនានុជនស្តាប់សន្និសីទក្តី ប្រជុំពិគ្រោះការផ្សេងៗក្តី ទទួលលៀងក្រយាហារក្តី ។ល។

យើងត្រូវកាត់សក់-កោរពុកមាត់ កោរពុកចង្កាឱ្យស្អាតបាតល្អៗ ទាំងក្រចកម្រាមដៃទៀតសោត ក៏ត្រូវកាត់ឱ្យខ្លីដែរ ដើម្បីកុំបង្ហាញការស្មោគគ្រោកទៅឱ្យអ្នកដទៃឃើញ កើតខ្ពើមរអើម ព្រោះការគួរសមរបស់អឺរ៉ុបគេរាប់អានខាងចាប់ដៃគ្នា ។ ចុះបើយើងហុចដៃយើងទៅគេក្តី ឬទទួលដៃលោកអ្នកហុចមកក្តី ដៃយើងមានក្អែលគ្រប់ក្រចកទាំងអស់ តើលោកអ្នកដែលស្អាត នឹងមានចិត្តភិតភ័យខ្លាចមេក្រូមីរបស់យើងយ៉ាងណាទៅ ? ដូច្នេះឃើញថា ការរៀបចំសម្លៀកបំពាក់ នឹងការសំអាតខ្លួនប្រាណឱ្យបានសមរម្យ ជាការប្រសើរ១យ៉ាងសំខាន់ សម្រាប់យើងរាល់គ្នាដែលត្រូវចូលទៅកាន់ទីប្រជុំជនធំ-តូច ។ ចុះបើយើងមិនកាន់ទម្លាប់នេះឱ្យជាឧក្រិដ្ឋទេ យើងគង់បានទទួលសេចក្តីរិះគន់អំពីជនទាំងឡាយជាមិនខាន ។

* *
*

បន្ទប់ទទួលភ្ញៀវ

តាមសម័យនិយមនៃអារ្យប្រទេស គេតែងចាត់ចែងទីលំនៅឱ្យមានកន្លែងសម្រាប់ដេក កន្លែងសម្រាប់បរិភោគអាហារ និងកន្លែងទទួលភ្ញៀវ ។ល។ (ឯផ្ទះបាយត្រូវទុកដោយឡែកអំពីផ្ទះធំ) ។

យើងរាល់គ្នាឥតមានរើសមុខថា ជាមន្ត្រី សេដ្ឋី គហបតី ឬរាស្ត្រសាមញ្ញទៀយ រមែងមានញាតិសាច់សាលោហិត និងមិត្រសំឡាញ់ ទៅមករាប់រកគ្នាជាធម្មតា ដោយសេចក្ដីមេត្រី ដោយសេចក្ដីឈឺឆ្អាល ដោយសេចក្ដីគួរសម ។

ដូច្នេះ. ផ្ទះសម្បែងយើងរាល់គ្នា គប្បីឱ្យមានកន្លែងសម្រាប់ទទួលភ្ញៀវ ។ បើទុកណាជាផ្ទះតូចចង្អៀតយ៉ាងណាក៏ដោយ ក៏ត្រូវតែឆ្លៀតយកកន្លែងមួយតូចល្មមដាក់តុតូច១នៅកណ្ដាល និងកៅអីជុំវិញតុនោះឱ្យបាន ។ កុំចូលចិត្តថា កន្លែងទទួលភ្ញៀវជាទីសម្រាប់តាំងរបស់ល្អផ្សេងៗ ដែលមានតម្លៃលើសលុបនោះឡើយ ។ បន្ទប់ទទួលភ្ញៀវជាកន្លែងដែលត្រូវ ដាក់តុកៅអីល្អៗ ស្អាតហើយរៀបចំឱ្យបានស្រួល ព្រោះជាទីប្រជុំមួយដែរ ។ ឯទីធំទូលាយនឹងតូចចង្អៀត ក៏អាចនឹងធ្វើបានតាមធនធាន តាមទំហំផ្ទះទេ ។ គេរៀបចំកន្លែងទទួលភ្ញៀវឱ្យល្អស្អាតជាដរាប រចនានៅដោយកន្ទេល-ព្រំ-ផើងឈើ-ផើងផ្កា-បំពង់ផ្កា-រូបសូន្យ និងរូបថតក៏ល្មមហើយ ។ របស់ដែលល្អពេក មានតម្លៃច្រើនពេក នោះគេពុំសូវយកមកតាំងក្នុងទីនេះទេ ដោយ

គេគិតថា របស់ទាំងនោះដូចជាចំណងចងភ្ញៀវមិនឱ្យកំរើកខ្លួនបានស្រួល ។ ភ្ញៀវបើឃើញរបស់ដែលល្អមានតម្លៃច្រើនពេករមែងរវាំង ប្រយ័ត្នខ្លួនដៃជើងក្រែងប៉ះទង្គិចធ្លាក់បែកបាក់មិនជាការគប្បី ហើយនាំបណ្តាលឱ្យម្ចាស់ផ្ទះអាក់អន់ស្រពន់ចិត្ត ស្តាយរបស់ដែលខូចនោះផង ។

នៅបន្ទប់ទទួលភ្ញៀវ មិនត្រូវយកនាឡិកាមកដាក់នៅជញ្ជាំង ឬតាំងនៅទីណាមួយ ដែលភ្ញៀវមើលទៅឃើញនោះឡើយ ព្រោះនាឡិកាហាក់ដូចជាវិញ្ញាណសម្រាប់ដាស់តឿនមនុស្សឱ្យដឹងថា "ម៉ោងប៉ុណ្ណេះហើយ ថាល្មមពេលធ្វើនេះធ្វើនោះហើយ" ។ល។

បន្ទប់ទទួលភ្ញៀវ ត្រូវនៅដោយឡែកអំពីកន្លែងបរិភោគអាហារ ។ តែគេហស្ថានឯណាដែលតូចចង្អៀត, ដូចផ្ទះល្វែង១ (ដែលយើងហៅថាផ្ទះផ្សារ) មានតែ១ច្រកនោះ យើងអាចរំលែកច្រកនោះជាពីរភាគទៅ ។ ភាគទី១ ខាងមុខ យើងត្រូវរៀបជាកន្លែងទទួលភ្ញៀវ ភាគបន្ទាប់ទៅខាងក្នុង ជាកន្លែងបរិភោគអាហារ, ដោយមានឡប់ឡែ ឬទូមួយតូច ឬឈើដាំជើង១ជើង ដាក់កណ្តាលជាជញ្ជាំងឃាំងញែកពីគ្នា ។

ការបោសច្រាសថែសំអាត និងបៀបរៀបរយក្នុងបន្ទប់ទទួលភ្ញៀវ ត្រូវធ្វើរាល់ព្រឹកឱ្យស្រេច ដោយប្រយ័ត្នក្រែងមានភ្ញៀវមកដល់ ផ្ទះនៅក្រខ្វក់រកកន្លែងឱ្យភ្ញៀវអង្គុយគ្មាន ។ ព្រោះភ្ញៀវចុះឡើងមិនមានកំណត់ឱ្យដឹងថាមកដល់ពេលនេះ ឬពេលនោះ ។

ភ្ញៀវនឹងអ្នកផ្ទះ

សាច់សាលោហិត មិត្រសំឡាញ់ជិតឆ្ងាយ នឹងព្រៀងលាន ដែលទៅលេងសួរសុខទុក្ខបងប្អូនមិត្រសំឡាញ់ ព្រៀងលានផងគ្នា នេះទុកជាភ្ញៀវស្និទ្ធស្នាលជិតដិតនឹងគ្នា គប្បីទទួលរាក់ទាក់ តាមយើងធ្លាប់រាប់អានគ្នាទាំងសងខាង តែងវាំងកុំឱ្យលើសហួសប្រមាណ [១] (គឺប្រយ័ត្នកាយ និងវាចាកុំឱ្យជ្រុលពេលក្នុងការស្និទ្ធ)។

ចំណែកភ្ញៀវដទៃឯទៀត ត្រូវកាន់គារវកិច្ចឱ្យបរិបូណ៌ ចំពោះអ្នកផ្ទះ ។ អ្នកផ្ទះវិញសោតក៏ត្រូវគោរពតបវិញឱ្យពេញលេញចំពោះភ្ញៀវ ។

នៅផ្ទះយើងគប្បីស្លៀកពាក់ឱ្យសមរម្យជាយ៉ាងកណ្ដាល ល្មមនឹងទទួលភ្ញៀវដែលមកលេងផង មិនចាំបាច់ផ្លាស់ប្តូរសម្លៀកបំពាក់ជាថ្មីទៀតទេ តែមិនមែនតែងខ្លួនឱ្យល្អឆើតឆាយដូចជាទៅមើលបុណ្យទេ ។

អ្នកជាភ្ញៀវអញ្ជើញទៅរកលោកអ្នកធំក្ដីតូចជាងក្ដី ស្មើគ្នាក្ដី ទៅដល់ហើយ ត្រូវគោរទ្វារផ្ទះឱ្យល្អឮដល់អ្នកនៅខាងក្នុង (បើយើងគ្មានជួបប្រទះនឹងមនុស្សណាម្នាក់សោះនៅមុខផ្ទះ) បើគោះទ្វារម្ដងហើយគ្មានគេបើកទ្វារឱ្យ ត្រូវបង្អង់ចាំមើលបាន១ស្របក់សឹមគោះទ្វារម្ដងទៀត ។ បើនៅតែគ្មានគេបើកទ្វារឱ្យ ឬមានមនុស្សនៅផ្ទះនោះចេញមកប្រាប់ថា "ម្ចាស់ផ្ទះមិននៅទេ" យើងត្រូវផ្ដាំនឹងអ្នកនោះថា យើងនាមជានេះ... ធ្វើការងារ

ជានោះ... ក្នុងក្រសួងនោះមករក ឬមួយផ្ញើនាមប័ត្រ១សន្លឹកទុកជូន (បើយើងគ្នាច្រើនត្រូវទុក១សន្លឹកម្នាក់) ។

ភ្ញៀវមុននឹងចូលទៅក្នុងបន្ទប់ ដែលគេសម្រាប់ទទួលយើង ត្រូវទុកមួក-អាវភ្លៀង-ដំបង នៅនារបៀងផ្ទះខាងក្រៅបន្ទប់ ឬនៅបន្ទប់តូចមួយ ដែលគេសម្រាប់ទទួលទុករបស់ទាំងនោះសិន សឹមចូលទៅ ។ របៀបស្រុកអឺរ៉ុប ស្ត្រីដែលពាក់មួកមិនដោះចេញទេ ត្រូវពាក់ចូលទៅអង្គុយទាំងមួកនៅលើក្បាល ។

សាសន៍ខ្លះ. ដូចជាចាម-ជ្វា-ក្លឹង-អារ៉ាប់-ភូមា-យួន... គេធ្លាប់ពាក់កាតិប គេមានឈ្នួតក្បាលជាទម្លាប់ធំ ជាប្រដាប់សម្រាប់គោរពធំ នោះទោះបីចូលក្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍ ក៏គេពុំដែលដោះចេញដែរ ។

ភ្ញៀវមិនត្រូវកាន់ដំបងចូលទៅក្នុងផ្ទះគេទេ តែបើភ្ញៀវនោះជាមនុស្សពិការ ឬចាស់ជរាត្រូវការដំបងសម្រាប់ទប់ខ្លួនឱ្យបានស្រួល អាចនឹងកាន់ដំបងចូលទៅដល់ទីអង្គុយបាន ។

អ្នកម្ចាស់ផ្ទះ មិនត្រូវទុកឱ្យភ្ញៀវឈរចាំនៅខាងក្រៅទ្វារបន្ទប់យូរពេកទេ ។ កាលណាឮសូរគេគោះទ្វារហើយ ត្រូវវ៉ាសរវៃចេញទៅបើកទ្វារទទួល ហើយអញ្ជើញចូលមកក្នុងកន្លែងដែលសម្រាប់ទទួលភ្ញៀវ ។ បើយើងចេញភ្លាម ដោយរួសរាន់ពុំបានទេ ត្រូវឱ្យបម្រើចេញទៅបើកទ្វារហើយអញ្ជើញភ្ញៀវចូលមកដោយគារវកិច្ចតាមសមគួរ ។ ត្រូវបង្គាប់

បម្រើឱ្យជំរាបភ្ញៀវថា "លោកខ្ញុំ ឬអ្នកខ្ញុំ កំពុងរវល់ជាប់ដៃ ឱ្យសូមទោសលោក-អ្នកសូមអញ្ជើញចាំបន្តិច" ហើយបម្រើនោះត្រូវអញ្ជើញភ្ញៀវឱ្យអង្គុយនៅកៅអីនាបន្ទប់នោះតាមសមគួរ ។

ភ្ញៀវគប្បីឈរបន្តិច ក្រែងអ្នកម្ចាស់ផ្ទះចេញភ្លាមតាមក្រោយបម្រើគេបើជាយឺតបន្តិច យើងអាចនឹងអង្គុយទៅបាន តែត្រូវរំពៃស្តាប់សូរជើងអ្នកផ្ទះ បើឮសូរដើរចេញជិតមកដល់មាត់ទ្វារហើយ ត្រូវយើងជាភ្ញៀវក្រោកឈរឡើងរង់ចាំគោរពអ្នកម្ចាស់ផ្ទះ ។

បើមានបារីនៅលើតុ ដែលអ្នកម្ចាស់ផ្ទះគេបម្រុងទុកទទួលភ្ញៀវនោះភ្ញៀវមិនត្រូវពិសារបារីនោះទេ នៅពេលដែលរង់ចាំអ្នកផ្ទះ ត្រូវអត់ធន់ទំរាំអ្នកផ្ទះចេញមកសិន ហើយគេលើកជូនដោយគោរព និងមេត្រីភាព ។

អ្នកផ្ទះជូនបារីភ្ញៀវហើយ គប្បីយកឈើគូសគូសជូនភ្ញៀវទៀតផង ។

នៅពេលដែលរង់ចាំអ្នកផ្ទះ ភ្ញៀវមិនត្រូវបើកមើលសៀវភៅផ្សេងៗរបស់អ្នកផ្ទះ ដែលគេទុកនៅលើតុនោះទេ បើអផ្សុកត្រូវមើលតែរូបគំនូរនៅជញ្ជាំងផ្ទះគេបានហើយ ។

អ្នកផ្ទះចេញមកទទួលភ្ញៀវ ៗ នឹងអ្នកផ្ទះត្រូវធ្វើគារវកិច្ចគួរសមនឹងគ្នាទៅវិញទៅមក ។

កិច្ចគារវៈនេះ ត្រូវកុំឱ្យភាន់ច្រឡំ គឺប្រុសត្រូវគោរពស្ត្រីមុន-នេះតើយ៉ាងណាមិញ ?

ថាបើអ្នកផ្ទះចេញមកទទួលទាំងភរិយាស្វាមី យើងជាភ្ញៀវ (ប្រុស-ស្រី) គប្បីធ្វើគារវកិច្ចចំពោះភរិយាអ្នកម្ចាស់ផ្ទះជាមុន ។ ផ្ទុយទៅវិញបើភ្ញៀវមកទាំងប្ដីប្រពន្ធ អ្នកផ្ទះប្រុសគប្បីធ្វើកិច្ចគួរសមនឹងភរិយាភ្ញៀវមុន រួចសឹមគួរសមនឹងប្រុសផងគ្នាខាងក្រោយ ។

តាមរបៀបខ្មែរ បុរសត្រូវលើកដៃសំពះគួរសមនឹងស្ត្រី មិនត្រូវចាប់ដៃស្ត្រីទេ លុះណាតែស្ត្រីអនុញ្ញាតហុចដៃមកឱ្យចាប់ ទើបចាប់បាន (ជាតិអឺរ៉ុប បុរស និងស្ត្រីអាចចាប់ដៃគួរសមនឹងគ្នាបានឥតទាស់) ។

កិច្ចនេះក៏ពុំដាច់ខាតដែរ ត្រូវគិតដល់ត្រកូលទៀតគឺថា:

១-ធម្មជាតិជារាស្ត្រ ត្រូវគោរពក្សត្រខត្តិយត្រកូលមុន ។

២-មន្ត្រីតូចត្រូវគោរពមន្ត្រីធំមុន ។

៣-រាស្ត្រត្រូវគោរពមន្ត្រីមុន ។

៤-ក្មេងត្រូវគោរពចាស់មុន ។

៥-សិស្សត្រូវគោរពគ្រូអាចារ្យមុន (ទុកជាសិស្សមានយសស័ក្តិធំជាងក៏ដោយ) ។

បើប្រសិនជាភ្ញៀវឱ្យដំណឹងមកអ្នកផ្ទះពីថ្ងៃមុនហើយ១ អ្នកផ្ទះបានណាត់ពេលវេលាជាស្រេច នោះអ្នកផ្ទះត្រូវរៀបចំខ្លួនប្រាណរង់ចាំភ្ញៀវ១ត្រូវមកឱ្យទៀតពេលម៉ោង កុំឱ្យខុសហួសពី៥នាទីនាឡិកាឡើយ ។

ត្រង់នេះអ្នកផ្ទះត្រូវបើកទ្វារបង្អួចផ្ទះទុកជាមុន បើឃើញភ្ញៀវមកដល់ ត្រូវដើរតម្រង់ចូលទៅទទួលតាមឋានៈភ្ញៀវ នឹងយើងជាម្ចាស់ផ្ទះ ។

គឺបើភ្ញៀវក្សត្រ យើងជារាស្ត្រសាមញ្ញ ត្រូវទៅទទួលអញ្ជើញស្ដេចឡើងតាំងពីព្រះទីនាំងរថមក ។

(ភ្ញៀវរដ្ឋមន្ត្រី និងយើងជារាស្ត្រក៏ដូចគ្នា) ។

ឋានៈថយមកទៀតខ្លះ ត្រូវទទួលនៅទ្វាររបងផ្ទះខ្លះជើងជណ្ដើរផ្ទះខ្លះ នៅមាត់ទ្វារផ្ទះខ្លះ ។

បើឋានៈស្មើគ្នា, ភ្ញៀវក្ដី អ្នកផ្ទះក្ដី គប្បីដើរចូលរកគ្នាត្រង់ទីណាក៏ត្រូវធ្វើគារវកិច្ចទៅវិញទៅមក នៅត្រង់នោះល្អជាង តាមសមគួរ ។

ឯក្សត្រខត្តិយសត្រកូល និងមន្ត្រីធំ លោកពុំត្រូវចេញមកទទួលយើងឡើយ សូម្បីតែត្រឹមមាត់ទ្វារជំណាក់-ផ្ទះ ក៏ពុំសមដែរ ។

រួចកិច្ចគោរពគួរសមនឹងគ្នាហើយ អ្នកផ្ទះត្រូវអញ្ជើញភ្ញៀវឱ្យអង្គុយ រួចទើបអ្នកផ្ទះអង្គុយក្រោយ លើកតែស្ត្រីអាចអង្គុយស្មើនឹងភ្ញៀវបាន ។

នៅខណៈនោះ, បើមានភ្ញៀវថ្មីមកទៀត ដោយភ្ញៀវមុនពុំទាន់លាចេញទៅវិញផង, អ្នកផ្ទះគប្បីសូមទោសភ្ញៀវមុនបន្តិច ចេញទៅទទួលភ្ញៀវថ្មីនោះមកទៀត ។ តែបើភ្ញៀវថ្មីជាមិត្រស្និទ្ធរបស់អ្នកផ្ទះ១ពុំបាច់ដើរចេញទៅទទួលទេ គ្រាន់តែក្រោកឈរឡើងហើយអញ្ជើញឱ្យចូលមកបានហើយ ។ នៅពេលនេះបើភ្ញៀវចាស់និងភ្ញៀវថ្មីជាជនពុំដែលស្គាល់គ្នា អ្នក

ផ្ទះគប្បីនាំភ្ញៀវទាំងពីរនេះឱ្យស្គាល់គ្នា (មានសេចក្ដីអធិប្បាយពន្យល់របៀបទៅខាងក្រោយ) ដើម្បីនឹងបាននិយាយលេងនឹងគ្នាខ្លះផងក្នុងគ្រានោះ ។

ភ្ញៀវមុនត្រូវដឹងថា យើងល្មមគួរសមនឹងលាគេហើយឬនៅ ? ត្រូវគិតក្រែងភ្ញៀវថ្មី មានកិច្ចអ្វីនិយាយនឹងអ្នកផ្ទះ ដោយកំបាំងមុខយើង. ដូច្នេះយើងត្រូវទទួលរាក់ទាក់នឹងភ្ញៀវថ្មីរបស់គេបន្តិចទៅ លៃពេលល្មមកុំឱ្យគេថាយើងឃើញគេហើយរត់ នោះត្រូវសុំលាតាមកាលគួរសម ។

* *
*

ការលាគ្នា

ភ្ញៀវត្រូវកុំភ្លេចខ្លួនអំពីម៉ោងពេលឱ្យសោះ ត្រូវរំពៃឱ្យញយបន្តិចគិតក្រែងអ្នកម្ចាស់ផ្ទះគេមានធុរៈផ្សេងៗតទៅទៀត ឬមានភ្ញៀវថ្មីទៀតមក ឬមានការប្រញាប់ចេញទៅណាមកណាទៀត ។ បើយើងឃើញអ្នកផ្ទះរាក់ទាក់រីករាយសប្បាយនឹងយើង ដោយយើងជាញាតិ ឬជាមិត្រស្និទ្ធនោះយើងក៏ត្រូវរវាំងកុំឱ្យសួរពីមួយម៉ោងឱ្យសោះ ដោយគិតក្រែងដល់ពេលម្ចាស់ផ្ទះគេអាស្រ័យបាយ ឬដល់ពេលគេត្រូវសម្រាក (គឺពេលគេដេក) កុំ

អង្គុយឱ្យយូរដល់ទៅម្ចាស់ផ្ទះគេធុញទ្រាន់នោះឱ្យសោះ ត្រូវមានបារម្ភក្នុងខ្លួនជានិច្ច ។

ក-ឧបមា, ដូចជាយើងបានអនុញ្ញាតពីអង្គក្សត្រខត្តិយត្រកូលមានព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាដើម ទ្រង់ប្រោសព្រះរាជទានឡើងក្រាបថ្វាយបង្គំគាល់ហើយ នោះយើងពុំត្រូវនឹងក្រាបថ្វាយបង្គំលាខ្លួនឯង ដោយពុំទាន់ព្រះរាជទានព្រះរាជានុញ្ញាតិនោះឡើយ ។ ឯព្រះរាជានុញ្ញាតឱ្យថ្វាយបង្គំលានោះមានកាលក៏មានព្រះរាជឱង្ការព្រះរាជទានថា "ទៅចុះ" មានកាលយើងត្រូវដឹងខ្លួនយើងថា ព្រះអង្គអស់ព្រះកាយពលហើយ នឿយព្រះអង្គណាស់ ដល់ពេលសោយហើយ ដល់ពេលចូលព្រះក្រឡាបន្ទំហើយ ។ល។ គង់តែទ្រង់ព្រះរាជទានសញ្ញាអ្វីមួយប្រទានយើងឱ្យដឹងចាំយើងក្រាបថ្វាយបង្គំលាបាន, បើពុំដូច្នោះទេ ត្រូវតែនៅគាល់ទាល់តែព្រះរាជទានឱ្យក្រាបថ្វាយបង្គំលា ។

ខ-បើបានអនុញ្ញាតទៅជួបនឹងលោកអ្នកធំនៅមន្ទីរធ្វើការ (ដូចជារដ្ឋមន្ត្រី ឬចៅហ្វាយនាយ) ក៏ត្រូវកុំភ្លេចគិតអំពីពេលវេលានឹងត្រូវលាចេញ ឬនឹងត្រូវបង្អង់ចាំស្តាប់ប្រសាសន៍ឱ្យអស់ការសិន ។

ដំណើរសន្ទនាគ្នាជាលំដាប់តាមរឿងរ៉ាវ ដែលយើងជំរាបសព្វគ្រប់ហើយលោកក៏បានតបមកវិញតាមហូរហែ នោះយើងគប្បីជំរាបលាដោយមើលកាល ។

មានកាលលោកមានប្រសាសន៍ថា ៖

អញ្ជើញទៅចុះចាំខ្ញុំមើលឱ្យ ឬមិនអីទេចាំខ្ញុំជួយគិតឱ្យ ឬរឿងនេះមិនស្រេចទេ ឬខ្ញុំអរគុណហើយ ឬកុំភ័យគិតតែ...ទៅ... ។ល។ ពាក្យទាំងប៉ុន្មាននេះ ជាឧទាហរណ៍គ្រាន់ជាបែបផែនឱ្យដឹង ជាពាក្យបញ្ចប់រឿងហើយព្រមទាំងឬកពារលោក ហាក់ដូចជាប្រាប់ថែមមកទៀតថា "ល្មមពេលហើយ" នោះយើងត្រូវជំរាបលាដោយរួសរាន់ ។

ជួនកាលមនុស្សបម្រើ ឬបណ្ណទូត (បួងតុង) ចូលមកជំរាបលោកថា "មានភ្ញៀវមកទៀត លោកនេះ, អ្នកនោះ អញ្ជើញមកសូមជួប" នោះយើងគប្បីរកឧបាយបញ្ចប់រឿងឱ្យឆាប់ទៅ នឹងជំរាបលាវិលវិញ កុំឱ្យមានការធុញទ្រាន់ ។

* *
*

ជូនដំណើរភ្ញៀវ

ដល់ពេលភ្ញៀវលាទៅវិញ អ្នកផ្ទះត្រូវជូនដំណើរភ្ញៀវតាំងពីបន្ទប់ដែលទទួលរហូតដល់មាត់ទ្វារបន្ទប់នោះ ឬដល់មាត់ទ្វារផ្ទះ ឬដល់មាត់ជណ្តើរ ឬដល់ទ្វាររបងភូមិ ឬដល់រទេះ ។ គឺថា កាលដែលភ្ញៀវមកដល់យើងទៅទទួលភ្ញៀវពីត្រង់កន្លែងណាមក យើងត្រូវជូនភ្ញៀវដល់ទៅត្រង់

កន្លែងនោះវិញ ។ តែបើភ្ញៀវជាវរជន ក្សត្រ ឬបុព្វការី មន្ត្រីធំចៅហ្វាយនាយនោះ គប្បីជូនដល់រថយន្តជាដរាប ។ អ្នកផ្ទះត្រូវឈរគួរសមនឹងភ្ញៀវទាល់តែរថចេញផុតទៅ ទើបអាចត្រឡប់ចូលមកផ្ទះវិញបាន ។ ភ្ញៀវនឹងអ្នកផ្ទះ ត្រូវធ្វើគារវកិច្ចទៅវិញទៅមកម្តងទៀត មុននឹងបែកចេញពីគ្នាទៅវិញ ។

ប្រសិនបើយើងមានភ្ញៀវពីរនាក់ផ្សេងគ្នា ភ្ញៀវមុនលាទៅវិញមុនដោយគេយល់អធ្យាស្រ័យភ្ញៀវក្រោយ នោះអ្នកផ្ទះគប្បីសូមទោសជូនដំណើរភ្ញៀវមុនទៅសិន ។ តែបើអ្នកផ្ទះចេញទទួលភ្ញៀវទាំងប្តីប្រពន្ធនោះត្រូវរំលែកគ្នាម្នាក់ជូនភ្ញៀវទៅសិន ម្នាក់នៅបដិសណ្ឋារៈនឹងភ្ញៀវក្រោយទើបគួរ មិនត្រូវជូនដំណើរទាំងអស់គ្នាចេញចោលភ្ញៀវក្រោយឱ្យនៅតែឯងទេ ។ សោតឯភ្ញៀវដែលលាទៅមុន គប្បីចូលចិត្តបានជាបើអ្នកផ្ទះចេញទទួលយើងតែម្នាក់ឯង ហើយក្រោកចោលភ្ញៀវក្រោយជូនដំណើរយើងមកនោះ ត្រូវនិយាយថា "អរគុណ" ហើយអង្វរឃាត់ថា "សូមកុំព្រួយ កុំបាច់ជូនអី សូមអញ្ជើញទៅគួរសមនឹងលោកនោះ អ្នកនោះទៅចុះ" ធ្វើយ៉ាងនេះ កិច្ចគារវៈទើបគ្រប់បរិបូរណ៍ឥតមានឆ្គង ។

* *
*

ការនាំឱ្យស្គាល់គ្នា

បានស្គាល់គ្នាច្រើនជាមិត្រភ័ក្តិ ជាមនុស្សរាប់អានគ្នាក៏ជាប្រយោជន៍សម្រាប់សង្គមនីមួយៗ ។ យើងអាចនឹងស្គាល់គ្នាបានដោយខ្លួនឯង ឬដោយអ្នកដទៃនាំឱ្យស្គាល់ តែមានជនខ្លះពុំឈ្វេងយល់ក្នុងការនាំគ្នាឱ្យស្គាល់គ្នាដោយធ្វេសប្រហែស ឬដោយពុំបានពាក្យសំដី ។

តាមប្រវេណីបុរាណខ្មែរយើង មិនមានការប្លែកប៉ុន្មានអំពីអារ្យធម៌អឺរ៉ុបឡើយ ។

មាតាបិតា ជីដូនជីតាយើងនាំយើងដើរលេង ឬទៅមើលបុណ្យទៅធ្វើបុណ្យឯវត្ត... ។ល។ នោះកាលណាលោកបានជួបប្រទះនឹងមិត្រលោកជាញាតិសាលោហិតក្តី ជាមនុស្សដែលលោកធ្លាប់រាប់អានក្តី លោកតែងតែបង្គាប់យើងជាកូន-ចៅឱ្យសំពះសួស្តីគេ ហើយលោកប្រាប់គេថា "នេះកូនខ្ញុំ, នេះចៅខ្ញុំ..." ។

យ៉ាងនេះ, ក្មេងដែលកំពុងចំរើនបញ្ញាវាងវៃឆាប់ចាប់អារម្មណ៍ចងចាំបានភ្លាម, ថ្ងៃក្រោយទៅ បានជួបប្រទះនឹងលោកនោះ អ្នកនោះទៀតក៏គោរពគួរសមតាមបង្គាប់មាតាបិតា ជីដូន ជីតា ដែលលោកបានប្រាប់អំពីថ្ងៃមុន ។

មិនតែប៉ុណ្ណោះទេ, កាលកូនប្រុសចំរើនធំគ្រប់អាយុ បួសជាសាមណេរ ជាភិក្ខុបាន លោករៀបចំបំបួស លោកបាននាំទៅលាញាតិ

សាលោហិត និងព្រៀងលានពាបួ៤ថ្ងៃមុននឹងបំបួស ។ លុះសិក្ខាចាកផ្នួសមកជាគ្រហស្ថវិញ ក៏នាំទៅគោរពសួរញាតិម្តងទៀត ។

ទីបំផុតបុត្រស្រីប្រុស ដែលមាតាបិតាជីដូនជីតាបានទុកដាក់ឱ្យមានគូស្រករជាភរិយាស្វាមីត្រឹមត្រូវតាមច្បាប់ទម្លាប់ប្រវេណីហើយ ក៏លោកតែងនាំកូនស្រីឱ្យស្គាល់ញាតិខាងប្រុស នាំកូនប្រុសឱ្យស្គាល់ញាតិខាងស្រី ទាំងនាំកូនទាំងពីរឱ្យទៅក្រាបបង្គំសូមពរពីព្រះសង្ឃឯវត្តទៀត គឺជាកិច្ចដែលកូនប្រុសត្រូវនាំភរិយាខ្លួន ទៅប្រគេនលោកគ្រូខ្លួន ឱ្យលោកបានស្គាល់ទៀតផង ។

* *
*

តាមរបៀបអារ្យធម៌សម័យនិយម

១-អ្នកផ្ទះនាំភ្ញៀវ និងភ្ញៀវឱ្យស្គាល់គ្នា ។ អ្នកផ្ទះត្រូវនាំភ្ញៀវថ្មីឱ្យស្គាល់ ភ្ញៀវដែលមកមុន ។ ភ្ញៀវដែលត្រូវអ្នកផ្ទះនាំឱ្យស្គាល់នោះ ត្រូវឈរទាំងអស់គ្នា ។ តែបើជាស្រីចាស់អាយុច្រើនជាង ហើយគេនាំឱ្យស្គាល់មនុស្សប្រុស ឬស្រីក្មេងជាង ស្រីចាស់នោះអាចនឹងទទួលបដិសណ្ឋារអង្គុយបាន ។

បើប្រសិនជាយើងទៅដល់ផ្ទះគេ ហើយភ្ញៀវមុនច្រើនគ្នាកំពុងតែចេញមក អ្នកផ្ទះពុំអាចនឹងនាំភ្ញៀវទាំងអស់ឱ្យស្គាល់គ្នាបានឡើយ. ដូច្នេះអ្នកផ្ទះគប្បីនាំឱ្យស្គាល់គ្នាម្នាក់ពីរបានដោយសេចក្ដីគួរសមយ៉ាងរួសរាន់ ។

ភ្ញៀវមិនស្គាល់គ្នា មិនអាចនឹងធ្វើការកិច្ចទៅវិញទៅមករកគ្នាបាន នោះបើអ្នកម្ចាស់ផ្ទះមិននាំឱ្យស្គាល់ជាការមិនគួរ ។ គេត្រូវនាំបុរសឱ្យស្គាល់ស្ត្រីក្មេងឱ្យស្គាល់មនុស្សចាស់ (ទាំងស្ត្រី-ទាំងបុរស) ឱ្យស្គាល់មន្ត្រីកវីបណ្ឌិត ។

មូលសេចក្ដីទៅគឺថា ត្រូវនាំមនុស្សក្មេងឱ្យស្គាល់មនុស្សចាស់ នាំក្រមុំឱ្យស្គាល់ស្ត្រីមានប្ដី នាំកំឡោះឱ្យស្គាល់បុរសមានប្រពន្ធ ។

* *
*

របៀបនាំភ្ញៀវឱ្យស្គាល់គ្នា

គេនាំមនុស្សប្រុសស្រីជាច្រើននាក់ ទៅជូនអ្នកធំម្នាក់ឱ្យស្គាល់ក្នុងទីប្រជុំឯណាមួយ ឬទៅពីធីអ្វីមួយ នោះគេត្រូវជំរាបឈ្មោះ និងការងារអ្នកនោះ ៗ ជូនអ្នកធំ តែគេមិនដែលយកនាមអ្នកធំមកប្រាប់អ្នកតូចវិញទេ នៅចំពោះមុខ. អ្នកតូចៗត្រូវលបដឹងឯង ឬអ្នកនាំត្រូវខ្សឹបប្រាប់ជាមុន ។

ប្រៀបដូចផ្លាស់ចៅហ្វាយខែត្រ:

លោកចៅហ្វាយខេត្តចាស់ ត្រូវនាំបណ្ដាខ្ញុំរាជការដែលនៅក្រោមបង្គាប់ទាំងប៉ុន្មានមកគួរសមនឹងលោកចៅហ្វាយខេត្តថ្មី នៅពេលដែលលោករដ្ឋមន្ត្រីអញ្ជើញទៅរៀបខេត្ត ។ នៅពេលដែលនាំមន្ត្រីក្រោមបង្គាប់ទៅជូនលោកចៅហ្វាយខេត្តថ្មីឱ្យស្គាល់ នោះលោកចៅហ្វាយខេត្តចាស់គប្បីបញ្ចេញនាម និងការងារប្រាប់លោកចៅហ្វាយខេត្តថ្មីថា នេះលោកប្រសើរ, នោះលោកភូឈួយខេត្តទី១, នេះលោកវិសេស ចៅហ្វាយស្រុក... ។ល។

* *
*

៣~របៀបនិយាយនាំភ្ញៀវឱ្យស្គាល់គ្នា

-សូមជំរាប់លោក នេះលោក ! (នាម និងងារការ) ។

-ជំរាបអ្នក នេះអ្នក (នាម និងរបររកស៊ី) ។ បើជាស្ត្រី និងស្ត្រីថាកាត់ខ្លី១ទៅក៏បាន :

-នេះលោកស្រី... (ចេញនាមស្វាមី)

-នេះអ្នកស្រី... (ចេញនាមស្វាមី) ។ បើចង់បង្ហាញថ្នាក់ និងឋានន្តរស័ក្តិត្រូវថា:

-សូមជំរាបលោកស្រី ! នេះលោកស្រីភរិយា លោកចៅហ្វាយស្រុក (នាម) ស្រុក..........ខេត្ត......។

-នេះអ្នកស្រី (នាម) ជាភរិយាលោក... (នាម) ជាកល្យាណមិត្ត របស់ខ្ញុំ ។

បើអ្នកម្ចាស់ផ្ទះនាំឱ្យស្គាល់រួចហើយ ភ្ញៀវទាំងពីរនាក់ត្រូវគោរពគ្នាទៅវិញទៅមក តែត្រូវភ្ញៀវដែលគេនាំឱ្យទៅស្គាល់នោះធ្វើកិច្ចគារពមុន [១] (គឺងក់ក្បាល ឬសំពះតាមគួរសម) គឺត្រូវនិយាយទៅកាន់ភ្ញៀវដែលនឹងទទួលបដិសណ្ឋារៈ) ដោយដំណើរផ្សេងៗ ដែលគួរផ្ដើមនិយាយឡើង ឱ្យបានជាការរាប់អានគ្នានៅពេលនោះ និងតទៅថ្ងៃក្រោយទៀត ។

បើជាបុរស និងបុរស ដែលត្រូវគេនាំឱ្យស្គាល់លោកនោះអ្នកនោះ គប្បីធ្វើគារវកិច្ចមុន (ងក់ក្បាល ឬសំពះ) នៅគ្រាដែលគេប្រាប់ហើយនូវនាមយើងទៅលោកនោះ អ្នកនោះ ។ មួយរំពេចនោះ, យើងត្រូវបន្លឺនូវវាចារថា :

-សូមប្រណិប័តន៍ ព្រះតេជគុណ,

-ជំរាបសួស្ដី លោកអ្នក,

-សូមប្រណិប័តន៍ដោយគោរព...

-សូមជំរាបសួស្ដីដោយស្មោះ... ។ល។

លោក-អ្នកដែលបានទទួលគារវកិច្ច ត្រូវធ្វើឱ្យគួរសមតបវិញភ្លាមៗ ដូចមានរបៀបខាងក្រោមនេះ :

-ជំរាបសួស្ដី លោកចាងហ្វាង,

-សុខសប្បាយទេ លោកចៅហ្វាយស្រុក,

-សុខទុក្ខយ៉ាងណាទៅ លោកក្មួយ.

-សប្បាយជាទេ លោក, អ្នក... ។ល។

បើតាមរបៀបទម្លាប់ទំនៀមប្រទេសអឺរ៉ុប អ្នកដែលគោរពមុនគេតែងតែបន្ថឹនូវងារការ ឬនាម នៃលោក-អ្នកឯណាដែលគេគោរពដូចមានតទៅ :

-សូមប្រណិប័តន៍ ព្រះតេជគុណ នាយករដ្ឋមន្ត្រី

-សូមគោរព លោកជំទាវ

-សូមជំរាបសួស្តី ឯកឧត្តមចៅហ្វាយខេត្ត... ។ល។

បើស្និទ្ធស្នាលនឹងគ្នាគេចេញនាមតែម្តង

-ជំរាបសួស្តី លោក... (នាម)

-សុខសប្បាយជាទេ លោក ... (នាម)

ជាទេ កនយើង ... ។ល។

លោកអ្នកដែលបានទទួលគារវកិច្ច ក៏ឆ្លើយគួរសមតបវិញភ្លាមៗរបៀបដូចគ្នា :

-លោក ចាងហ្វាងជាទេ.

-លោក គ្រូពេទ្យ សុខសប្បាយទេ.

-លោក សៅរ៍ សុខ ជាទេ.

-លោក ម៉ៅ សប្បាយទេ... ។ល។

កិរិយាបំពេញនូវគារវកិច្ចទៅមករកគ្នា គប្បីបន្ទន់ខ្លួនឱនក្បាលទៅមកជាជរាប ទោះសំពះក្ដី គំនាប់ចាប់ដៃក្ដី ។

បើបុរសធ្វើគារវកិច្ចចំពោះស្ត្រី ដោយកិរិយាងក់ក្បាលគោរព និងបន្លឺនូវវាចាគួរសម ហើយថាៈ

-សូមប្រណិប័ត្រន៍ លោកជំទាវ,

-សូមជំរាបសួរ្ដី លោកស្រី,

-សូមគោរពអ្នកស្រី

-ជំរាបសួរ្ដី នាងកញ្ញា ។ល។

នោះគប្បីបង្អង់ចាំឱ្យស្រីហុចដៃមកមុន ទើបបុរសហុចដៃទៅទទួលគំនាប់ជាខាងក្រោយ ។

បើគេនាំយើងឱ្យស្គាល់អ្នកធំណាមួយ ដែលយើងមានប្រាថ្នាចង់ស្គាល់ យើងមិនត្រូវចរចារទៅកាន់លោក ដោយដំណើរចចាកអារាក់រួសរាន់ពន់ពេកទេ ។ យើងត្រូវនិយាយមួយម៉ាត់ៗម្ដង ដោយដំណើរសុភាពរៀបរយល្អ ព្រមទាំងកិរិយាបង្ហាញឫកពារគោរពឱ្យគ្រប់គ្រាន់ផង មិនត្រូវចាប់ឱបរិតស្និទ្ធស្នាលឱ្យហួសប្រមាណពេក ។

* *
*

កិច្ចគួរសមតាមផ្លូវ

នៅតាមផ្លូវបើមានជនណាមួយ ដែលយើងមិនស្គាល់សោះ មកសួរដណ្តឹងយើងពីការផ្សេងៗ ឬប្រសិនបើនៅទីប្រជុំសាធារណជន ឬនៅលើយានជំនិះជាមួយនឹងយើងនោះ អ្នកនៅជិតខាងយើងនិយាយគ្នាក្តី និយាយមករកយើងក្តី យើងអាចនឹងឆ្លើយឆ្លងទៅបាន ដោយពុំបាច់ប្រាប់ឈ្មោះនាមយើងឱ្យស្គាល់ឡើយ ។

ប៉ុន្តែបើយើងជួបប្រទះនឹងជនម្នាក់ ដែលមិនស្គាល់ ហើយដែលយើងស្មានថាជននោះនឹងមានទាក់ទងក្នុងសមាគមយើង ក្នុងពួកគណៈយើង ក្នុងរបរអាជីវៈយើងទៅអនាគត នោះដំណើរទទួលស្គាល់ក៏ត្រូវតែប្រាប់នាមជាការចៀសពុំរួច ដោយជាប្រយោជន៍របស់យើង ។

ក្នុងកិច្ចគារវៈ ចំពោះជនពីរនាក់ដែលមិនស្គាល់គ្នា ហើយមានគេនាំឱ្យស្គាល់ នោះនៅគ្រាដែលគោរពចាប់ដៃគំនាប់គ្នាដំបូង ត្រូវប្រាប់ឈ្មោះគ្នាទៅវិញទៅមក (តាមទម្លាប់ប្រទេសអឺរ៉ុប) តាមបែបផែនដូចមានតទៅ :

បុរសប្រាប់តែគោត្របាន បើចង់ប្រាប់នាមខ្លួនផង លុះត្រាតែជាការខានមិនបាន ព្រោះប្រទេសអឺរ៉ុបច្រើនច្រឡំនាមខ្លួន បើគោត្រមិនច្រឡំទេ ដូចជាឈ្មោះ : ហ្សង់ -ប៉ូល-ពីរយុរ... ។ល។ នេះឃើញថា ដូចៗគ្នា តែបើរាប់គោត្រវិញឃើញខុសៗគ្នា ...។

ស្ត្រីមានប្ដី ត្រូវប្រាប់គោត្រប្ដីគេ គេតែងដាក់ពាក្យអ្នកស្រីពីមុខគោត្រប្ដីគេ ដើម្បីដឹងថា គេមានប្ដីហើយ ។

ស្រីក្រមុំ ត្រូវប្រាប់តែនាមខ្លួនបានហើយ បើជាគ្រូពេទ្យត្រូវដាក់ងារការនៅមុខគោត្រ ។ បើជាទាហានត្រូវដាក់យសស័ក្ដិនៅមុខគោត្រ ។ តែរបៀបនេះក៏មិនជាសំខាន់ប៉ុន្មានទេ ។

ឯទម្លាប់ទំនៀមខ្មែរយើង ដែលធ្វើគារវកិច្ចទៅមករកគ្នា ដោយកិរិយាថ្វាយបង្គំ-សំពះ នោះពុំបាច់ប្រាប់គោត្រ ឬនាមគ្នាឡើយ ។ បើចង់ស្គាល់លោកអ្នកធំ ឬលោកដែលមានអាយុច្រើន អាចនឹងសួរដណ្ដឹងតាមការគយរសមថា អ្នកនេះឈ្មោះអ្វី ? នៅឯណា ? ធ្វើការរកស៊ីអ្វី ? យ៉ាងនេះជាដើម ។

មិត្រយើងពីរនាក់មិនស្គាល់គ្នា ជួនជាជួបគ្នានៅចំពោះមុខយើង នៅផ្លូវតែម្នាក់ដើរជាមួយនឹងយើង នោះយើងគប្បីតែធ្វើគារវកិច្ច ដោយបើកមួក ឬងក់ក្បាល ឬសំពះ ឬចាប់ដៃ និយាយគួរសម សួរសុខទុក្ខមួយម៉ាត់ពីរ ពុំចាំបាច់នាំអ្នកទាំងពីរឱ្យស្គាល់គ្នាទេ ។ ឯអ្នកដែលដើរជាមួយនឹងយើង មិនត្រូវចូលនិយាយជាមួយផងទេ ត្រូវតែដើរឱ្យឃ្លាតឆ្ងាយបន្តិចទៅទើបគួរ ។

* *
*

លៀងក្រយាហារ

តាមប្រវេណីប្រទេសកម្ពុជាយើង ធម្មតានៃខេមរជាតិតែមានធ្វើបុណ្យទានអ្វីក្តី រៀបពិធីអ្វីក្តី តែងតែមានលៀងខាទនីយភោជនីយាហារបណ្តាមិត្រញាតិ និងព្រៀងលាន ដោយមេត្រីរាប់អានគ្នា ។ របៀបលៀងក្រយាហារនេះ គេតែងតែអញ្ជើញភ្ញៀវស្រីជាមួយនឹងស្រី ប្រុសជាមួយនិងប្រុស ។ កន្លែងរៀបក្រយាហារនោះ សព្វថ្ងៃនេះគេច្រើនរៀបចំជូនស្រីៗនៅខាងលើផ្ទះ ប្រុសៗនៅនារោងខាងក្រោម គឺនៅមុខផ្ទះ ឬចំហៀងផ្ទះដោយតុខ្ពស់និងកៅអី ។ បើផ្ទះគេធំ ភ្ញៀវគេតិច នោះគេរៀបរួមគ្នានៅលើផ្ទះទាំងអស់ ។

របៀបដែលរៀបនៅលើផ្ទះ ពីបុរាណកាលមក ច្រើនរៀបអាហាររាបផ្ទាល់នឹងកន្ទេល គេដាក់តុមួយទាប កំពស់ប្រមាណ២០សង្ទីម៉ែត្រ ទំហំប្រហែល១ម៉ែត្របួនជ្រុងស្មើ. តុនីមួយៗមានក្រាលកម្រាលសពីលើ ទើបរៀបម្ហូប ចាន បាយ. សម. ស្លាបព្រាប្រាំមួយ ឬប្រាំពីរសម្រាប់ គឺសម្រាប់ចំនួនភ្ញៀវប្រាំមួយ ឬប្រាំពីរនាក់ ។ គ្រប់គ្រាន់ហើយទើបអញ្ជើញទៅកាន់ទីកន្លែងពិសាក្រយា ។ គេតែងមានកន្ថោរសំរាប់ភ្ញៀវចោលរបស់ដែលអស់ត្រូវការមានឆ្អឹងត្រីជាដើម ។ គេមានផ្តិលទឹក ឬកែវទឹក កន្សែងជូតដៃឱ្យគ្រប់បរិបូណ៌មិនឱ្យខ្វះខាតតាមត្រូវការ ។ របៀបនេះ រៀបទាល់តែគ្រប់ចំនួនភ្ញៀវទាំងស្រីទាំងប្រុស ។ គ្រាកាលរៀបចំរួចស្រេចហើយ អ្នកផ្ទះត្រូវអញ្ជើញភ្ញៀវពិសាដោយរួសរាន់ ។ ពេល

នេះអ្នកផ្ទះត្រូវដឹងឋានៈនៃភ្ញៀវអញ្ជើញរួមតុផងគ្នា ឱ្យសមរម្យតាមអធ្យាស្រ័យផង តាមពួកបក្សផង :

១-គប្បីអញ្ជើញចាស់ព្រឹទ្ធាចារ្យអ្នករក្សាសីលរួមតុកជាមួយគ្នា ។

២-គប្បីអញ្ជើញមន្ត្រី ជាមួយមន្ត្រី ។

៣-គប្បីអញ្ជើញលោកអ្នកពិសាសុរាជាមួយអ្នកសេពសុរាផងគ្នា ។

៤-គប្បីអញ្ជើញសាមញ្ញជន ជាមួយសាមញ្ញជនផងគ្នា ។

៥-មានលោកអ្នកខ្លះពុំប្រកាន់យសស័ក្តិទេ លោកចូលចិត្តរួមជាមួយនឹងពួកបក្ស ជាមួយនឹងមិត្រភ័ក្តិ ជាមួយនឹងក្រុមការងារ ជាមួយនឹងសង្គម ។ ត្រង់នេះអ្នកម្ចាស់ផ្ទះពុំគប្បីនឹងទទឹងចិត្តភ្ញៀវឡើយ ព្រោះដំណើរដែលភ្ញៀវរើសកន្លែងរើសអ្នករួមតុជាមួយនោះ ដើម្បីឱ្យស្រួលចិត្ត ចៀសវាងមនុស្សដែលទាស់អធ្យាស្រ័យគ្នា ហើយទើបបានពិសាក្រយាដោយរីករាយចិត្ត ។ ទុកណាជាម្ហូបពុំសូវល្អក៏ត្រង់គាប់ចិត្តនឹងមិត្ររួមតុដែរ ។

រៀបភ្ញៀវហើយ អ្នកផ្ទះត្រូវបម្រើភ្ញៀវឱ្យដឹងគ្រប់គ្រាន់ ឬខ្វះខាត កុំចោលភ្ញៀវតាមតែអ្នកបំរើឡើយ ។ ត្រូវតែតាមត្រួតមើលឱ្យគ្រប់វង់ គ្រប់តុ ឱ្យដឹងថា ត្រូវថែមបាយ សម្ល... ។ល។ ឬភ្ញៀវត្រូវការអ្វីទៀត ។ បើអ្នកម្ចាស់ផ្ទះទទួលបដិសណ្ឋារៈក្នុងការលៀងភោជនាហារនេះពុំបានបរិបូណ៌ទេ គប្បីតែពឹងគេឯងឱ្យជួយមើលការខុសត្រូវជួសខ្លួនក៏បាន ។

មានកាលខ្លះ ក្នុងឱកាសរៀបអាពាហ៍ពិពាហ៍ អ្នកខ្លះហៅភ្ញៀវទៅចោលតាមតែផឹកស៊ីខ្លួនឯងជាមួយនឹងអ្នកបម្រើទៅចុះ លោកអ្នកសាមីដើមការ ពុំអាចនឹងដឹងបាន. ធ្វើយ៉ាងនេះពុំគួរគប្បីសោះឡើយ ។

វេលាដែលភ្ញៀវកំពុងពិសា លោកអ្នកដើមការ ដែលចេញឈ្មោះអញ្ជើញភ្ញៀវ ត្រូវតែដើរគួរសមនឹងភ្ញៀវគ្រប់ៗវង់ហើយបន្ទន់វាចារសួរថា "ឆ្ងាញ់ពិសា ឬយ៉ាងណាទៅ" ទាំងសម្ដែងសេចក្ដីមេត្រីអរគុណផង ។

របៀបនេះ អាចធ្វើបានទាំងខាងភ្ញៀវប្រុស-ទាំងខាងភ្ញៀវស្រី. គ្រាលៀងរួចហើយ យើងត្រូវរំពៃមើល បើឃើញភ្ញៀវរៀបចំខ្លួននឹងលាអ្នកផ្ទះខាងស្រីគប្បីរកទីកន្លែងត្រង់ណាមួយ ល្មមភ្ញៀវស្រីលាបាន ខាងប្រុសសោតទៀតអ្នកផ្ទះខាងប្រុសក៏ត្រូវនៅឯមាត់ទ្វាររបងផ្ទះ ចាំគួរសមទទួលជូនដំណើរភ្ញៀវដែលលាទៅវិញ ។

របៀបនេះសម្រាប់តែសាមញ្ញជនទេ ។ បើព្រះមហាក្សត្រិយ៍ខត្តិយត្រកូលវិញព្រះអង្គប្រោសព្រះរាជទានលៀងសព្វមុខមន្ត្រីកវីបណ្ឌិត នោះបណ្ដាយើងជាខ្ញុំ ក្រោមលួងធូលីព្រះបាទ កាលចូលមកក៏ត្រូវចូលទៅក្រាបថ្វាយបង្គំដល់កន្លែងដែលព្រះអង្គគង់រង់ចាំភ្ញៀវ និងថ្វាយបង្គំលាវិញ យើងក៏ត្រូវចូលក្រាបបង្គំលាដល់ទី ដែលព្រះអង្គទ្រង់ប្រថាប់នោះវិញដែរ ។

ភ្ញៀវដែលចូលមកទទួលព្រះរាជទានលៀង តាមព្រះរាជឱង្ការត្រាស់អញ្ជើញនោះៗកាលមកដកល់ព្រះមហាប្រាសាទហើយ មើលឃើញព្រះអង្គហើយត្រូវដើរតម្រង់ចូលទៅក្រាបថ្វាយបង្គំកុំបង្អង់ កុំងាកឆ្វេងស្ដាំគួរសមនឹងភ្ញៀវដូចគ្នាឡើយ ។ ថ្វាយបង្គំហើយទើបគួរសមនឹងភ្ញៀវដូចគ្នាជាខាងក្រោយចុះ ។

គារវកិច្ចនេះមិនមែនចំពោះតែព្រះមហាក្សត្រិយ៍មួយព្រះអង្គទេ គឺទូទៅត្រូវយើងជាភ្ញៀវគប្បីតែគួរសមនឹងម្ចាស់ផ្ទះជាមុនសិន សឹមគួរសមនឹងភ្ញៀវដូចគ្នាជាខាងក្រោយ ទាំងកាលមកដល់ និងកាលលាត្រឡប់ទៅវិញ ។

១ទៀត. តាមប្រពៃណីខ្មែរ តែភ្ញៀវមកដល់ហើយអ្នកផ្ទះត្រូវទទួលបដិសណ្ឋារៈអញ្ជើញឱ្យអង្គុយនៅទីមួយដ៏សមគួរ រួចត្រូវជូនបារី ស្លា ទឹកក្ដៅ ទឹកត្រជាក់ តាមការគួរ ។

ដល់ភ្ញៀវពិសាក្រយាហាររួច ក៏ត្រូវជូនម្ដងទៀតសំរាប់លាងមាត់. ដូចទឹកតែក្ដៅៗ កាហ្វេ ឬសុរាអ្វីមួយបែប ដែលគេប្រើសម្រាប់ទទួលទានក្រោយអាហារ ។

* *
*

របៀបបរិភោគអាហារ

កាលបើអ្នកផ្ទះរៀបក្រយាហារសព្វគ្រប់ហើយ ភ្ញៀវត្រូវរៀបចំខ្លួនប្រាណឱ្យបានស្រួលបួលនឹងពិសាក្រយា ។ ត្រូវយកសមស្លាបព្រាចេញពីក្នុងចានបាយមកគងផ្ទាប់នៅមាត់ចាន ចាំទទួលបាយដែលអ្នកបំរើយកមកជូន ។ ស្លាបព្រាត្រូវគងលើមាត់ចានខាងស្ដាំដៃ សមត្រូវគងលើមាត់ចានខាងឆ្វេងដៃ ។ តែបើអ្នកបំរើពុំទាន់បានយកបាយមកជូនភ្ញៀវ និងពិសាក្រយាលេងបណ្ដើរសិនក៏ស្រួលដែរ ។ បើអង្គុយរាប មិនត្រូវអង្គុយច្រត់ដៃផ្ទៀងត្រគៀកឡើយ ព្រោះជាការនាំឱ្យរំខានដល់អ្នកអង្គុយជិតខាងគ្នា ។

កិរិយាដែលនឹងបរិភោគអាហារក្នុងឱកាសលៀងធំក្ដី តូចក្ដី ក្នុងវង់នីមួយៗលោកអ្នកទាំងឡាយ គប្បីអញ្ជើញលោកអ្នកដែលចាស់ជាងគេ ឬដែលមានយសខ្ពស់ជាងគេ ឱ្យពិសាមុន១មាត់ទៅ ទើបយើងរាល់គ្នាបរិភោគជាលំដាប់មក ។

ដំណើរបរិភោគអាហារក្នុងទីប្រជុំនេះ ត្រូវប្រើឫកពាឱ្យសមរម្យដោយសុភាពរបៀបរយមិនកញ្ចក់កញ្ចែង ច្រងេងច្រងាងទើសគេទើសឯងដែលនៅជិត ។ មិនត្រូវឡើបឡប់ក្រខ្វេកក្រខ្វប់ទាល់តែកើតមានសេចក្ដីមិនស្អាត ឱ្យគេខ្ពើមរអើម ឱ្យគេធុញទ្រាន់ឡើយ ។

* *
*

លក្ខណៈដែលនឹងបរិភោគឱ្យល្អ

១-ដៃដែលកាន់ស្លាបព្រា គេត្រូវកាន់ផ្ងារបាតដៃ ទំនងដូចជាកាន់ដងប៉ាកា គេមិនផ្កាប់ដៃ ឬក្ដាប់ដៃទេ ។

២-កិរិយានឹងដួសចាប់យកម្ហូបមកដាក់ក្នុងមាត់ គេពុំដួសឱ្យទាល់តែពេញស្លាព្រា ទាល់តែហូរហៀរស្រក់ស្រោក់ប្រឡាក់កម្រាលតុនោះឡើយ ។

៣-នឹងដាក់ម្ហូបចំណីទៅក្នុងមាត់ គេពុំហាមាត់ឱ្យធំពេកទេ គេពុំលៀនអណ្ដាតទទួលអាហារទេ គេពុំងើបក្បាលហើយបានហាមាត់ទទួលអាហារទេ គឺពុំឱនពេក ពុំងើបពេក ធ្មេញសោតទៀតក៏មិនត្រូវឱ្យប៉ះនឹងស្លាបព្រាទាល់តែឮសូរឡើយ ។

៤-អាហារគឺបាយនឹងម្ហូបដែលរាប់ថា១មាត់នោះៗ ពុំមែនញាត់ឱ្យទាល់តែពេញមាត់ប៉ោងថ្ពាល់ទាំងសងខាងនោះឡើយ ។

៥-ពុំទាន់ទំពារលេបអស់១មាត់គេពុំត្រូវដាក់បន្ថែមទៅទៀតទេ ។

៦-ដៃទាំងពីរដែលលើកដាក់ចុះឡើង គេបង្រួមកែងដៃឱ្យនៅតាមទំហំខ្លួន ពុំឱ្យច្រងេងច្រងាងក្ងួយដៃ ទើសនឹងដៃអ្នកអង្គុយជិតខាងទេ ។

៧-អាហារដល់មាត់ហើយ គេមិនស្រូបអាហារឱ្យឮត្រួកៗនោះទេ គេមិន ទំពាឱ្យឮភ្ជប់ៗទេ ។

៨-បាយដៃលេចូកនឹងស្លាព្រា គេចូកឱ្យល្មមឱ្យមូលត្រកួលក្នុងស្លាបព្រា កុំឱ្យលើកឡើងដាក់ក្នុងមាត់ ហើយជ្រុះពីមាត់មកក្នុងចានវិញទេ ។

៩-គេមិនយកម្ហូបណា១មុខ ដែលត្រូវមាត់ខ្លួន មកប្រឡាក់បាយដូចញាំ ឬស្រូបបាយដោយទឹកសម្លណាមួយមុខឡើយ ។

១០-គេមិនចាប់រំលែកម្ហូបណា១មុខឱ្យបានច្រើន មកដាក់ក្នុងចានបាយខ្លួនទេ ។

១១-គេមិនបរិភោគតែម្ហូបណា១មុខ ដែលខ្លួនត្រូវមាត់ ឬដែលឆ្ងាញ់ ជាងគេនោះទេ ។

១២-គេមិនបរិភោគរឡិបរឡប់ញាប់ដៃគ្មានបង្អង់ឱ្យ បានតែឆ្អែតមុនគេនោះទេ ។

១៣-គេតែងតែមើលនាយមើលអាយ កុំយឺតពេក កុំញាប់ពេក បើនឹង ឈប់ក៏ត្រូវឈប់បន្តៗគ្នា ឬស្មើគ្នាក្នុងវង់ជាមួយគ្នា ។

១៤-គេមិនដែលទារថែមតែម្ហូបណា ដែលឆ្ងាញ់នោះទេ ។ គេត្រូវរអែងអធ្យាស្រ័យដល់អ្នកម្ចាស់ផ្ទះ ក្រែងខ្វះខាតផង ។ យើងឃើញហើយម្ហូបបារាំងនិងចិន ភ្ញៀវពុំដែលទារថែមសោះឡើយ ។ ដំណើរថែមម្ហូបនេះស្រេចនៅអ្នកបំរើ បើគេសុំយកចានទទេទៅថែម ជាការគួរល្អមើលជាងភ្ញៀវទារឱ្យថែម ។ របៀបបារាំងមានកាលអ្នកបំរើកាន់ម្ហូបមកជូនភ្ញៀវសុំថែម ជូនដែរ តែភ្ញៀវខ្លះទទួល ខ្លះក៏ទេ ។

១៥-គេពុំដែលទាររករបស់ដែលខុសទំនងនោះឡើយ ឬរបស់ដែលគេពុំដាក់ឱ្យ ។ បើប្រសិនជាសាបប្រៃយ៉ាងណា គេស៊ូទ្រាំនៅស្ងៀម ។ ប្រៀបដូចគេលៀងម្ហូបចិន, ចិនទទួលទានទឹកស៊ីអ៊ីវ យើងទាររកទឹកត្រីយួន ឬទឹកត្រីបារាំង ។ យ៉ាងនេះជាកិរិយាមិនល្អមើល ហើយទាំងនាំឱ្យមានការខ្វល់ដល់អ្នកបំរើទៀត ផង ។

១៦-គេមិនដែលចោលឆ្អឹងត្រី ឬឆ្អឹងអ្វីនៅលើតុបាយសោះទេ គេចោល តែក្នុងកន្ថោរ ឬទុកក្នុងចានបាយរបស់ខ្លួននៅមាត់ចាន ឬនៅជ្រុងចាន ។

១៧-គេមិនឱ្យទង្គិចសមស្លាបព្រានឹងចានបាយ ឬចានសម្លឱ្យឮខ្លាំងទេ ។

១៨-គេមិនដែលទុកម្ហូប ដែលមានឱជារសឆ្ងាញនោះ នៅតែនាមុខខ្លួនទេ ត្រូវផ្លាស់ប្តូរកន្លែងម្ហូបខ្លះ ដើម្បីជាការគួរសមដល់លោកអ្នកដែលលូកមិនដល់ ឬដែលពិបាកនឹងឈោងឱ្យដល់ ។

១៩-កាលណាគេលែងបរិភោគចំអាប គេពុំដែលបរិភោគបង្អែមមុនគេឯងតែម្នាក់ឯងទេ គេរមែងបង្អង់ចាំឱ្យហើយគ្រប់គ្នា ទើបគេបរិភោគឱ្យស្មើគ្នា ។

២០-បើកាលណាបរិភោគហើយមានសាច់ ឬអ្វីមួយចូលសៀតស៊កនៅចន្លោះធ្មេញគេនឹងចាក់ឆ្កឹះយកចេញលុះត្រាតែឈើទ្រាំពុំបាន ។ បើទ្រាំបានគួរតែកុំអាលចាក់ បើមានភ្ញៀវតុជាមួយគេមិនទាន់លែង កុំឱ្យមានការខ្ពើមរអើមដល់គេ ដែលកំពុងបរិភោគ ។ កិរិយាចាក់ធ្មេញនេះ ត្រូវគេយកដៃម្ខាងខ្ទប់មាត់ ឬបាំងមាត់ កុំឱ្យអ្នកដទៃឃើញធ្មេញនៅក្នុងមាត់ និងមាត់ដែលហាឡើងនោះមិនជាទីទស្សនាការដល់ភ្នែកអ្នកទាំងពួង ។

២១-កាលបើលែងបរិភោគហើយ ត្រូវប្រមូលសម និងស្លាបព្រាដាក់ផ្គារ ទន្ទឹមគ្នានៅកណ្តាលចានបាយ ។ យ៉ាងនេះអ្នកបំរើអាចនឹងដឹងបានថា យើងឈប់ហើយ ។

២២-ឈប់បរិភោគហើយ គេមិនដែលលាងដៃដាក់ក្នុងចានបាយឡើយ គេមិនដែលលាងមាត់ ឬខ្ពុរមាត់នៅកន្លែងនោះឡើយ ។ គេមិនដែលខ្វល់នឹងចាក់ ទឹកលោងគ្រលែងចានបាយឡើយ ។

២៣-កាលបើបរិភោគលែងមុនគេ កុំអាលប្រញាប់ដក់បារីបង្ហុយផ្សែងដាក់គេដែលកំពុងបរិភោគមិនទាន់រួចនោះ ។

២៤-ពេលកំពុងបរិភោកមិនត្រូវខាកស្តោះឡើយ ។ បើកណ្តាស់ ឬក្អកទប់មិនបាន ក៏ត្រូវងាកមុខចេញពីតុ ឬយកកូនកន្សែងខ្ទប់មាត់ កុំឱ្យព្រូសបាយ ឬទឹកមាត់ចូលស្លកបាយឡើយ ។

របៀបបរិភោគអាហារ មិនសម្រាប់តែគ្រហស្ថទេ ទាំងព្រះសង្ឃក៏គប្បីប្រើឬកពាកិរិយាឱ្យស្រគត់ស្រគំ សមរម្យដូចបរិយាយមកខាងលើនេះដែរ ព្រោះព្រះសង្ឃរមែងតែឆាន់ចង្ហាន់រាបផ្ទាល់នៅកន្ទេលដែរ ។

តាមរបៀបអនាម័យបច្ចុប្បន្ននេះ ខ្លះគេដាក់ស្លាបព្រាក្នុងចានសម្ល១ ទុកជូនភ្ញៀវដួសម្លរនោះដាក់ក្នុងចានបាយខ្លួន ដើម្បីចៀសវាងរោគឆ្លង ដោយយកស្លាព្រាដែលយើងដាក់ក្នុងមាត់ទៅដួសម្លរក្នុងចានតែមួយឯម្ហូបគ្រៀមពុំបាច់ទេ ដោយប្រើសមគ្រប់គ្រាន់ហើយ ។

* *
*

ថ្នាំជក់

ថ្នាំជក់មានក្លិនឈ្ងុយឆ្ងាញ់បានតែពពួកអ្នកជក់ថ្នាំដូចគ្នាទេ ។ ឯចំណែកអ្នកមិនចេះជក់ថ្នាំ មិនដែលសប្បាយរីករាយនឹងផ្សែងបារី ឬខ្សៀឡើយ ។

គេតែងក្រោកដើរចៀសចេញឆ្ងាយអំពីអ្នកជក់ ដោយទ្រាំទ្រក្លិនថ្នាំជក់ពុំបាន ។

ហេតុនេះយើងអ្នកជក់បារី ឬខ្សៀមានសេរីជក់បានតាមអំពើចិត្ត ឥតគិតកោតក្រែង តែកាលណាយើងនៅតែម្នាក់ឯង ឬនៅជាមួយអ្នកជក់ដូចគ្នា ។ នៅក្នុងទីប្រជុំនីមួយៗ ឬនៅក្នុងយានជំនិះ ដែលសម្រាប់ដឹកនាំសាធារណជនដូចជា រថយន្ត រថភ្លើង ។ល។ នោះយើងអ្នកជក់ថ្នាំត្រូវមានការប្រយ័ត្នរាំងមើលឆ្វេង-ស្តាំ តើជនទាំងឡាយដែលអង្គុយជិតយើងនោះ គេជក់ថ្នាំដែរឬទេ បើគ្មាននរណាជក់ទេ ហើយយើងត្រូវការជក់នោះគប្បីនិយាយគួរសមសុំទោសគេថា "ខ្ញុំសុំទោសទទួលទានបារីបានទេ" ។ អ្នកទាំងនោះបើទុកណាជាគេពុំចេះជក់ក៏ពុំអាចឃាត់ឡើយ គង់តែគេសន្តោសដល់យើង ។ គេតបដោយសមគួរមកវិញថា "អញ្ជើញ ពិសាចុះ" យ៉ាងនេះជាកិច្ចគារពមួយទៅមករកគ្នា ។ កាលណាយើងអុជបារីហើយកុំគប្បីបង្ហុយផ្សែងទៅលើមុខមាត់គេឯងរាល់គ្នាឡើយ សូម្បីតែអ្នកជក់ថ្នាំដូចគ្នាក៏ពុំគួរដែរ ។

មុននឹងចូលទៅក្នុងផ្ទះគេក្តី ចូលទៅក្នុងបន្ទប់គេធ្វើការ (ការិយាល័យ) ណាក្តី ឡើងរថដែលដឹកនាំអ្នកដំណើរក្តី រថភ្លើងក្តី... ។ល។ គប្បីតែចោលកន្ទុយ បារីពីមាត់នោះចេញសិន បើជាខ្សៀក៏គប្បីតែលត់ទុកទៅសិនដែរ ។

បើយើងជួបប្រទះនឹងជនណាមួយនៅនាផ្លូវ បើយើងត្រូវធ្វើគារវកិច្ច ចំពោះជននោះៗ យើងត្រូវយកបារី ឬខ្សៀអំពីមាត់ចេញសិនសឹមគោរព ។

នៅមុខជនណាម្នាក់ក៏ដោយ ដែលយើងអង្គុយនិយាយគ្នាលេងក្តី ឬច្រើននាក់ដែលប្រជុំគ្នាក្តី នោះមិនគប្បីនឹងបៀមបារីនៅបបូរមាត់ឡើយ ត្រូវតែបឺតម្តងយកចេញម្តងមកកាន់នៅដៃ ហើយសឹមដាក់ទៅបឺតទៀត យ៉ាងនេះ លុះត្រាតែអស់ បារីទើបចោលកន្ទុយ ។